# ផែនការយុទ្ធសាស្ត្រ

## ២០១៦ – ២០២០




### កែសម្រួល ខែ ធ្នូ ឆ្នាំ ២០១៦

# មាតិការ


**ចំណាប់អារម្មណ៍របស់ក្រុមប្រឹក្សាភិបាល**......1
**អារម្ភកថា**......2
**យើងជានរណា?**......3
អត្តសញ្ញាណ......3
ទស្សនៈវិស័យ......3
បេសកកម្ម......3
គោលដៅ......3
គុណតម្លៃ......3
យើងធ្វើការជាមួយនរណា?......3
**លក្ខណៈពិសេសរបស់យើង**......4
**កម្មវិធីស្នូលរបស់ អ.ជ.ក**......5
ការបង្កើតមជ្ឈមណ្ឌលជនជាតិដើមភាគតិច......6
គាំទ្រ និង អភិវឌ្ឍអ្នកដឹកនាំជនជាតិដើមភាគតិច......6
បង្កើតបណ្តាញជនជាតិដើមភាគតិច និង ពង្រឹងកិច្ចសហប្រតិបត្តិការ......7
កសាង និង ពង្រឹងសមត្ថភាពជនជាតិដើមភាគតិច......7
**យុទ្ធសាស្ត្រ ២០១៧ – ២០២០**......8
យុទ្ធសាស្ត្រទី ១ ៖ គ្រប់គ្រងការអនុវត្តន៍កម្មវិធីស្នូលរបស់អង្គការ ឱ្យឆ្លើយតបទៅតាមតម្រូវការរបស់អ្នកពាក់ព័ន្ធដែលជាជនជាតិដើមភាគតិច......9
យុទ្ធសាស្ត្រទី ២ ៖ ការតស៊ូមតិ និង ជួយរដ្ឋាភិបាលឱ្យពន្លឿនដំណើរការចុះបញ្ជីដី សហគមន៍......9
យុទ្ធសាស្ត្រទី ៣ ៖ ពង្រឹងជីវភាព និង សកម្មភាពសេដ្ឋកិច្ចរបស់សហគមន៍ ជ.ត......10
យុទ្ធសាស្ត្រទី ៤ ៖ ពង្រឹងសមត្ថភាពរបស់អង្គការ ដើម្បីប្រតិបត្តិការការងារប្រកបដោយ គុណភាពនិងមានប្រសិទ្ធភាពខ្ពស់ 11
យុទ្ធសាស្ត្រទី ៥ ៖ ស្វែងរកធនធានគាំទ្រកម្មវិធីការងារ និង ដំណើរការរបស់អង្គការ......12
**គោលបំណងយុទ្ធសាស្ត្រ សូចនាករ មធ្យោបាយវាស់វែង និង លទ្ធផលចំបងៗ**......13
**ការវាស់វែងផលប៉ះពាល់កម្មវិធី**......37
ការអនុវត្តផែនការ......37
ការត្រួតពិនិត្យ និង វាយតម្លៃ......37
ការធ្វើរបាយការណ៍......38
**ឯកសារភ្ជាប់ទី ១៖ បរិបទអភិវឌ្ឍក្នុងប្រទេសកម្ពុជា**......39
ប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ន......39
ជំហររដ្ឋាភិបាលក្នុងការអភិវឌ្ឍជនជាតិដើមភាគតិច......40
ដី និង ធនធានធម្មជាតិ......41

ផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ (NP-SNDD 2010-2019) ផ្តោតជាសំខាន់លើការបង្រួប បង្រួមរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ ស្រុក និង ខេត្ត និង អនុវត្តន៍ស្តង់ដារ 41
យែនឌ័រ និង ការពង្រឹងភាពអង់អាចដល់ស្ត្រី ..... 42
ផ្នែកឯកជន ..... 42
វិស័យឯកជនបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា ។ មានការទទួលស្គាល់កាន់តែច្រើនឡើងនូវភាពចាំបាច់ក្នុងការសហការរវាងរដ្ឋ និង ផ្នែកឯកជនដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គម ។..... 42
គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពរបស់អង្គការសហប្រជាជាតិ..... 43
**ឯកសារភ្ជាប់ទី ២៖ ដំណើរការចុះបញ្ជីដីសហគមន៍**..... 44
**ឯកសារភ្ជាប់ទី ៣៖ វិភាគចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និង ការគំរាមកំហែង អ.ជ.ក** ...46

# ចំណាប់អារម្មណ៍របស់ក្រុមប្រឹក្សាភិបាល

យើងជាក្រុមប្រឹក្សាភិបាល នៃអង្គការជនជាតិដើមភាគតិចកម្ពុជា មានការជឿជាក់ថា អង្គការអ.យ.កនិងអនុវត្តន៍ផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំ ដើម្បីបម្រើផលប្រយោជន៍អោយជនជាតិដើមភាគតិចនៅកម្ពុជា។ ការទទួលបាននូវការគាំទ្រពីម្ចាស់ជំនួយនិងប្រើប្រាស់ឲ្យមានប្រសិទ្ធិភាព និងប្រសិទ្ធិផលក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ ហើយយើងសូមលើកទឹកចិត្តឲ្យ អ.យ.ក ជាតួអង្គដើរតួរជាគន្លឹះក្នុងការគាំទ្រអនុវត្ត និងចាត់ទុកផែនការយុទ្ធសាស្ត្រនេះដូចជាផែនទីបង្ហាញផ្លូវ។

យើង សូមលើកទឹកចិត្តជាខ្លាំងដល់គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់របស់អ.យ.ក ដើម្បីបន្តអនុវត្តផែនការយុទ្ធសាស្ត្ររហូតដល់ពេលវេលាណាមួយដែលយើងគិតថាមានតម្រូវការកែសម្រួលឡើងវិញ។

ក្រុមប្រឹក្សាភិបាល

**លោកស្រីសៅ សុធារី**
**ប្រធានក្រុមប្រឹក្សាភិបាល**
**ថ្ងៃទី................................**

# អារម្ភកថា

អង្គការជនជាតិដើមភាគតិចកម្ពុជា(អ.ជ.ក)បានបង្កើតនិងចុះបញ្ជីនៅក្រសួងមហាផ្ទៃនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ (ស.ជ.ណ ១៣៥២)។ អង្គការបង្កើតឡើងដើម្បីធ្វើការផ្លាស់ប្តូរជោគ វាសនារបស់សហគមន៍ជនជាតិដើមភាគតិច ឱ្យទទួលខុសត្រូវដោយខ្លួនឯងចំពោះវប្បធម៌និង ប្រពៃណីនិងសិទ្ធិរបស់ពួកគេក្នុងការគ្រប់គ្រងដីធ្លីនិងធនធានធម្មជាតិនៅក្នុងសហគមន៍របស់ពួកគេក៏ដូចជាក្នុងប្រទេសកម្ពុជា ។

អ.ជ.ក មានជំនឿមុតមាំថា ជនជាតិដើមភាគតិច (ជ.ត) ដែលមានចំណេះដឹងជ្រៅជ្រះ អំពីបរិបទ ជ.ត អាចធ្វើការយ៉ាងមានប្រសិទ្ធិភាព (ជាមួយដៃគូរ និង អ្នកពាក់ព័ន្ធទាំងអស់) ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងពិតប្រាកដ និង មាននិរន្តរភាពសម្រាប់សង្គម ជ.ត។ អ.ជ.ក បង្កើតឡើងដោយស្ត្រីជនជាតិដើមភាគតិចព្នងមកពីខេត្តមណ្ឌលគិរី[1]។ អ.ជ.ក ដឹកនាំនិងគ្រប់ គ្រងដោយ ជ.ត ដែលមានចំណេះដឹងជ្រៅជ្រះពីសង្គម ជ.ត (ទាំងនៅមូលដ្ឋាន និង អន្តរជាតិ) និង សង្គមកម្ពុជា និង មានសមត្ថភាពពេញលេញក្នុងការជួយ និងឆ្លើយតបទៅនឹងតម្រូវការ របស់ ជ.ត នៅកម្ពុជា ។

ចាប់តាំងពីបង្កើតមក អ.ជ.ក បានទទួលបទពិសោធន៍ មតិយោបល់ និង គំនិតច្នៃប្រឌិតជា ច្រើនពីមនុស្សនៅជុំវិញខ្លួន ទាក់ទងនឹងអភិក្រមនៃការលើកកំពស់សិទ្ធិ និង ការអភិវឌ្ឍសង្គម និង សេដ្ឋកិច្ចរបស់ ជ.ត នៅកម្ពុជា ។ សេវាកម្មរបស់ អ.ជ.ក ត្រូវតាមតម្រូវការអភិវឌ្ឍន៍រយៈពេលវែងរបស់ ជ.ត រួមមាន ៖ ការកំណត់អត្តសញ្ញាណ ការលើកកំពស់សិទ្ធិក្នុងការគ្រប់គ្រងដីធ្លី និង ធនធានធម្មជាតិ និង ទីផ្សារសហគមន៍ ។ យើងអនុវត្តការងារដើម្បីលើកកំពស់ ជ.ត ឱ្យទទួលខុសត្រូវចំពោះជោគវាសនារបស់ពួកគេម្នាក់ៗ ចំពោះគ្រួសារ និង ចំពោះសហគមន៍ ជ.ត ទាំងមូល ។ ឧទាហរណ៍ ៖ យើងបានធ្វើការតស៊ូមតិជាមួយក្រសួងផែនការឱ្យធ្វើជំរឿន និង ចងក្រងព័ត៌មានជាក់លាក់អំពី ជ.ត ដើម្បីធ្វើជាមូលដ្ឋានសម្រាប់អភិវឌ្ឍ ជ.ត នៅកម្ពុជា ។ យើងបង្កើនភាពអង់អាចដល់ ជ.ត និង ចូលរួមសម្របសម្រួលដំណើរការចងក្រងសហគមន៍ (ជាមួយ ជ.ត) ដើម្បីធ្វើជាយន្តការគោលបម្រើផលប្រយោជន៍ដល់ ជ.ត នៅក្នុងសហគមន៍នីមួយៗ ។ យើងសម្របសម្រួលដំណើរការចុះបញ្ជីដីធ្លីសហគមន៍ និង ផ្តល់ជំនួយផ្នែកច្បាប់ដល់ ជ.ត នៅពេលពួកគេត្រូវការ ។

ផែនការយុទ្ធសាស្ត្រ ២០១៦ – ២០២០ បន្តផ្តោតការយកចិត្តទុកដាក់ចំពោះលទ្ធផល និង បង្ហាញអំពីអភិក្រមរបស់ អ.ជ.ក ក្នុងការអភិវឌ្ឍន៍ដែលផ្តល់ប្រយោជន៍រួមដល់សង្គម និង ធ្វើឱ្យមានការផ្លាស់ប្តូរសង្គម ជ.ត ក៏ដូចជាសង្គមកម្ពុជាទាំងមូល ។

ផែនការយុទ្ធសាស្ត្រនេះត្រូវបានធ្វើការពិនិត្យ និង កែសម្រួលនៅចុងឆ្នាំ ២០១៦ បន្ទាប់ពីបានធ្វើការពិភាក្សាយ៉ាងល្អិតល្អន់ជាមួយអ្នកពាក់ព័ន្ធទាំងអស់ ។ ការកែសម្រួល គឺដើម្បីធ្វើឱ្យមានលក្ខណសាមញ្ញ និង មានអភិក្រមរឹងមាំសម្រាប់តម្រង់ទិស អ.ជ.ក ឱ្យបង្កើនល្បឿន និង បង្កើនផលប៉ះពាល់ និង និរន្តរភាព នៃការផ្លាស់ប្តូរនៅក្នុងសង្គម ជ.ត។

---

[1] លោកស្រី យុន ម៉ាណេ ៖ នាយិកាប្រតិបត្តិអង្គការ អ.ជ.ក ជាជនជាតិដើមភាគតិចព្នងមកពីខេត្តមណ្ឌលគិរី ។ សហស្ថាបនិកអង្គការ អ.ជ.ក គឺលោក សេក សោភ័ណ (ជាអតីតមន្ត្រីសម្របសម្រួលថ្នាក់គម្រោងជនជាតិដើមភាគតិចរបស់អង្គការ ILO-ITP ចាប់តាំងពីខែឧសភាឆ្នាំ ២០០៥ ដល់ ខែមិថុនាឆ្នាំ២០១៥) គឺជាជនជាតិខ្មែរដែលមានដែលមានបទពិសោធន៍ជ្រៅជ្រះផ្នែកច្បាប់ និង កិច្ចការទាក់ទងនឹង ជ.ត។ បុគ្គលិកស្ម័គ្រចិត្តសំខាន់បីនាក់(កញ្ញាចាន់ ពេជ្រនារី លោកស្រីឡាត់ សុខឯម និងលោកផៃ សុវណ្ណា)បានបម្រើការងារតាំងពីអង្គការករកើត។

# យើងជានរណា?

## អត្តសញ្ញាណ

អ.ជ.ក គឺជាអង្គការដឹកនាំដោយជនជាតិដើមភាគតិច (ជ.ត) ដែលមានចំណេះដឹងជ្រៅជ្រះអំពី ជ.ត និង សង្គមកម្ពុជា និង មានសមត្ថភាពឆ្លើយតបប្រកបដោយភាពច្នៃប្រឌិតចំពោះតម្រូវការរបស់ ជ.ត នៅកម្ពុជា ។

## ទស្សនៈវិស័យ

អ.ជ.ក ចង់ឃើញ ជ.ត មានសមត្ថភាព និង សកម្មក្នុងការលើកកំពស់សហគមន៍ ជ.ត ឱ្យក្លាយជាសហគមន៍ អចិន្ត្រៃយ៍ និង រស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរនៅក្នុងសង្គមពហុវប្បធម៌ជាតិកម្ពុជា ។

## បេសកកម្ម

បេសកកម្មរបស់ អ.ជ.ក គឺដើម្បីធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាព សិទ្ធ និង និរន្តរភាពក្នុងការអភិវឌ្ឍន៍ របស់សហគមន៍ ជ.ត តាមរយៈការពង្រឹងស្មារតី ជ.ត ឱ្យមានភាពជាម្ចាស់លើដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង ការអភិរក្សវប្បធម៌ និង ប្រពៃណី។

## គោលដៅ

គោលដៅរបស់ អ.ជ.ក គឺដើម្បីកសាងសមត្ថភាព និង បង្កើនភាពអង់អាចដល់ ជ.ត ឱ្យដឹកនាំ និង ធ្វើជាម្ចាស់លើដំណើរការអភិវឌ្ឍសហគមន៍ ជ.ត នៅកម្ពុជា ។

## គុណតម្លៃ

- ភាពជាអ្នកដឹកនាំ ៖ យើងជឿជាក់លើសក្តានុពលរបស់មនុស្ស (ជាពិសេសស្រ្តីនិងយុវជន) ក្នុងការអភិវឌ្ឍន៍ និង កំណត់គោលដៅរបស់ពួកគេ ។
- គ្មានការរើសអើង៖ យើងឱ្យតម្លៃលើទំនាក់ទំនងស្មើភាពគ្នាដោយមិនប្រកាន់ជាតិពន្ធុ ឋានៈ ឋានានុក្រម ភេទ អាយុ ប្រវត្តិ និង និន្នាការនយោបាយអ្វីឡើយ ។
- សុចរិតភាព និង គណនេយ្យភាព ៖ យើងឱ្យតម្លៃសុចរិតភាព ហើយយើងប្រកាន់ខ្ជាប់នូវគណនេយ្យភាព ចំពោះអ្នកពាក់ព័ន្ធទាំងអស់។
- សាមគ្គីភាព និងការលះបង់៖ យើងឱ្យតម្លៃលើសាមគ្គីភាព ហើយយើងមានស្មារតី និង ឆន្ទៈរួមគ្នាក្នុងការអភិវឌ្ឍន៍ ជ.ត ប្រកបដោយនិរន្តរភាព ។

## យើងធ្វើការជាមួយនរណា?

អ.ជ.ក បំពេញការងារជាមួយអ្នកពាក់ព័ន្ធផ្សេងៗដូចជា ៖

1. សហគមន៍ជនជាតិដើមភាគតិច (ស.ជ.ត)
2. អង្គការសង្គមស៊ីវិល រួមមានអង្គការក្រៅរដ្ឋាភិបាល និង សហគមន៍មូលដ្ឋាន
3. រដ្ឋបាលថ្នាក់ក្រោមជាតិ
4. ស្ថាប័ន និង នាយកដ្ឋានរបស់រដ្ឋាភិបាល
5. វិស័យឯកជនដែលមានគោលដៅអភិវឌ្ឍសង្គម
6. ដៃគូរអភិវឌ្ឍន៍(រួមទាំងភ្នាក់ងារអង្គការសហប្រជាជាតិ)

# លក្ខណៈពិសេសរបស់យើង

អ.ជ.ក យល់ថាបញ្ហារបស់ ជ.ត នៅកម្ពុជាកើតមានឡើងនៅក្នុងបរិយាកាសអភិវឌ្ឍន៍ដ៏ស្មុកស្មាញ ។ យើងត្រូវមើលឱ្យគ្រប់ជ្រុងជ្រោយ[2]មុនពេលសម្រេចចិត្តធ្វើការផ្លាស់ប្តូរ ។ ការយល់ដឹងរបស់យើងអំពី ជ.ត និង បរិយាកាសអភិវឌ្ឍន៍របស់កម្ពុជាមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធទី ១ ។ អភិក្រមកម្មវិធីការងាររបស់យើងផ្តោតលើសកម្មភាពជាក់លាក់ដែលពង្រឹងស្មារតី ជ.ត ឱ្យមានភាពជាម្ចាស់ និង ផ្តល់ភាពអង់អាចដល់ពួកគេឱ្យដឹកនាំការងារអភិវឌ្ឍន៍ដែលនាំមកនូវការផ្លាស់ប្តូរពិតប្រាកដដល់សហគមន៍ ជ.ត ។ យើងកសាងទំនាក់ទំនងស៊ីជម្រៅ និងប្រកបដោយទំនុកចិត្ត ដើម្បីជួយ ជ.ត ឱ្យកំណត់អំពីការផ្លាស់ប្តូរ និង ធ្វើសកម្មភាពជាវិជ្ជមានត្រូវតាមគុណតម្លៃរបស់ពួកគេ ។ ជាមួយគ្នានេះដែរ យើងធ្វើកិច្ចការរបស់យើង ដើម្បីផ្តល់នូវលក្ខខ័ណ្ឌ និង ធនធានសមស្រប ដើម្បីឱ្យ ជ.ត បានចូលរួមក្នុងការងារសង្គម និង មានការផ្លាស់ប្តូរជាវិជ្ជមានចំពោះជីវិតរបស់ពួកគេ ។

យើងរីករាយនឹងធ្វើការសហការជាមួយស្ថាប័នផ្សេងៗទៀត ដើម្បីពង្រីកសកម្មភាពរបស់យើងឱ្យសម្រេចបាននូវផលប៉ះពាល់ជាអតិបរិមា ។

ការយល់ដឹងស៊ីជម្រៅរបស់យើងអំពីបរិបទរបស់ ជ.ត ទាំងនៅមូលដ្ឋាន ថ្នាក់ជាតិ និង សកល បានជួយឱ្យយើងធ្វើការយ៉ាងមានប្រសិទ្ធភាពក្នុងការផ្លាស់ប្តូរសង្គម ជ.ត ជាវិជ្ជមាន និង មាននិរន្តភាព ។ យើងមានវិធីសាស្ត្រចំរុះដែលអាចជួយឱ្យយើងមានភាពបត់បែនក្នុងការអនុវត្តឈានទៅសម្រេចបាននូវផលប៉ះពាល់ជាវិជ្ជមាន ។ វិធីសាស្ត្រទាំងនោះរួមមាន ៖ ការតស៊ូមតិដើម្បីឱ្យមានការធ្វើជំរឿន ជ.ត និង បង្កើតមជ្ឈមណ្ឌល ជ.ត ការសម្របសម្រួលចងក្រងសហគមន៍ ការបង្កើតបណ្តាញ និង កិច្ចសហប្រតិបត្តិការរវាងក្រុមពាក់ព័ន្ធផ្សេងៗគ្នា ផ្តល់ការគាំទ្រ និង អភិវឌ្ឍន៍អ្នកដឹកនាំ ជ.ត កសាង និង ពង្រឹងសមត្ថភាព ជ.ត និង សម្របសម្រួល ជ.ត ឱ្យទទួលបានជំនួយផ្នែកច្បាប់ ។ វិធីសាស្ត្រទាំងអស់នេះជួយឱ្យ អ.ជ.ក អាចអនុវត្តសកម្មភាពឆ្លើយតបទៅតាមតម្រូវការជាក់ស្តែងរបស់ សហគមន៍ ជ.ត ។

យើងបង្ហាញពីការយកចិត្តទុកដាក់របស់យើងចំពោះគុណភាពកម្មវិធីការងារ និង ការរៀនសូត្រ តាមរយៈការពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រ និង ការសិក្សាវាយតម្លៃកម្មវិធីការងារ ។

---

[2] បញ្ហាដែលជាប់ពាក់ព័ន្ធជាមួយនឹង ជ.ត ទាំងនៅមូលដ្ឋាន ថ្នាក់ជាតិ និង សកល

# កម្មវិធីស្នូលរបស់ អ.ជ.ក

គេមិនអាចយកវិធីតែមួយមកអនុវត្តដើម្បីធ្វើការផ្លាស់ប្តូរគ្រប់ស្ថានភាពរបស់សង្គមបានទេ ។ អ.ជ.ក សិក្សាគ្រប់ជ្រុងជ្រោយអំពីស្ថានភាពរបស់ ជ.ត និង អនុវត្តវិធីសាស្ត្រចំរុះ ដែលធ្វើឱ្យមានការចូលរួម និង ផ្លាស់ប្តូរជាវិជ្ជមានចំពោះសង្គម ជ.ត ។

ផ្អែកលើបុគ្គលិកដែលមានបទពិសោធន៍ចំរុះ អ.ជ.ក អនុវត្តន៍កម្មវិធីស្នូលចំនួនបួន ដែលទាក់ទងគ្នា និង ដែលសំខាន់សម្រាប់ធ្វើឱ្យមានការផ្លាស់ប្តូរជានិរន្តនៅក្នុងសហគមន៍ ជ.ត ។

លក្ខណៈពិសេសរបស់ អ.ជ.ក គឺការយល់ដឹងរបស់យើងដែលកំណត់ថា មុនពេលមានការអភិវឌ្ឍន៍កើតឡើង ចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរការគិតរបស់មនុស្សម្នាក់ៗ ដោយផ្តោតទៅលើគុណតម្លៃ ជំនឿ និង ហេតុផលដែលបង្កើតឱ្យមានឧបសគ្គផ្សេងៗ ។ វិធីសាស្ត្រដែលអនុវត្តនៅក្នុងកម្មវិធីស្នូលរបស់យើង ជួយឱ្យមានលំហរសម្រាប់ធ្វើការ ឆ្លុះបញ្ចាំងខ្លួនឯង និង ជួយមនុស្សឱ្យបង្កើតរបៀបគិតថ្មី។ ទាំងអស់នេះគឺជាមូលដ្ឋានគ្រឹះសម្រាប់ធ្វើការផ្លាស់ប្តូរដ៏ពិតប្រាកដ ។

*ដ្យាក្រាមទី ១ ៖ កម្មវិធីស្នូលរបស់ អ.ជ.ក*



## *ការបង្កើតមជ្ឈមណ្ឌលជនជាតិដើមភាគតិច*

អ.ជ.ក យល់ថាការងារអភិវឌ្ឍន៍ត្រូវផ្សារភ្ជាប់ជាមួយនឹងមនុស្ស ។ អ.ជ.ក ធ្វើការតស៊ូមតិ និង គាំទ្ររដ្ឋាភិបាលឱ្យធ្វើជំរឿន ជ.ត និង ចេញរបាយការណ៍ជាក់លាក់ និង បង្កើតយុទ្ធសាស្ត្រ និង ផែនការច្បាស់លាស់ដើម្បីអភិរក្ស និង អភិវឌ្ឍគ្រប់សហគមន៍ ជ.ត នៅកម្ពុជា ។

អ.ជ.ក មានមហិច្ឆិតាចង់កៀរធនធានសម្រាប់បង្កើតសារមន្ទីរ ជ.ត ដើម្បីបម្រើជាមជ្ឈមណ្ឌលព័ត៌មានដែលរក្សាទុក និង ផ្សព្វផ្សាយនូវព័ត៌មាន វប្បធម៌ និង ប្រពៃណីយ៍របស់ ជ.ត ក្នុងគោលបំណងរក្សាអត្តសញ្ញាណអចិន្ត្រៃយ៍របស់ ជ.ត និង សុខុមាលភាពនៅក្នុងសង្គមកម្ពុជា ។ លើសពីនេះទៀតសារមន្ទីរ ជ.ត មិនត្រឹមតែបង្កើតឡើងដើម្បីអភិរក្សវប្បធម៌ និង ប្រពៃណី ជ.ត ប៉ុណ្ណោះទេ ក៏ប៉ុន្តែវាក៏នឹងក្លាយទៅជាកេរ្តិ៍មរតកសម្រាប់ក្មេងជំនាន់ក្រោយនៅក្នុងកម្ពុជាទាំងមូល ។

## *គាំទ្រ និង អភិវឌ្ឍអ្នកដឹកនាំជនជាតិដើមភាគតិច*

អ.ជ.ក ជឿជាក់លើសមត្ថភាពរបស់ ជ.ត (ដែលមានចំណេះដឹងជ្រៅជ្រះអំពីបរិបទនៅមូលដ្ឋាន) ក្នុងការដឹកនាំដើម្បីបង្កើតឱ្យមានការផ្លាស់ប្តូរពិតប្រាកដ និង ប្រកបដោយនិរន្តភាពសម្រាប់សង្គម ជ.ត ។

យុទ្ធសាស្ត្រមួយរបស់ ជ.អ.ក គឺផ្តល់នូវទីកន្លែង និង ធ្វើការអភិវឌ្ឍន៍សមត្ថភាព និង ផ្តល់ភាពអង់អាចដល់ ជ.ត ណា ដែលមានសក្តានុពលក្នុងការរៀនសូត្រ និង រីកចម្រើន និង មានឆន្ទៈចូលរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គម ជ.ត ។ យើងអនុវត្តយុទ្ធសាស្ត្រនេះតាមរយៈកម្មវិធីចំនួនពីរ ៖

- កម្មវិធីហាត់ធ្វើការនៅក្នុងការិល័យ ៖ យើងបង្កើតកម្មវិធីដែលមានរយៈពេលមួយឆ្នាំសម្រាប់ ជ.ត (ជាពិសេសស្ត្រី និង យុវជន) ដើម្បីឱ្យពួកគេមកហាត់រៀនគ្រប់កិច្ចការក្នុងការិយាល័យ ។ កិច្ចការទាំងអស់នោះរួមមាន ភាពជាអ្នកដឹកនាំ ការងារគ្រប់គ្រង ការងាររដ្ឋបាល ការងារគណនេយ្យ ការងារកម្មវិធី និង បច្ចេកទេស ។ ក្រោយរយៈពេលមួយឆ្នាំ អ្នកហាត់ការនឹងរកឱកាសដើម្បីបម្រើសង្គម ជ.ត ក៏ដូចជាសង្គមកម្ពុជាទាំងមូល ។
- គាំទ្រដល់សកម្មជន (ដែលល្បីនៅក្នុងសហគមន៍) ៖ អ.ជ.ក ជម្រុញ និង គាំទ្រសកម្មជន ជ.ត (ជាពិសេសស្ត្រី និង យុវជន) ដែលសកម្មចូលរួមដឹកនាំសកម្មភាពតស៊ូមតិ និង ការងារអភិវឌ្ឍន៍នៅក្នុងសហគមន៍ ។ អ.ជ.ក មានទិសដៅកៀរ និង ចងគ្រងអ្នកទាំងអស់នោះឱ្យក្លាយជាតំណាងនៅក្នុងសហគមន៍របស់ពួកគេនៅថ្នាក់ក្រោមជាតិ និង ថ្នាក់ជាតិ ឬនៅលើឆាកអន្តរជាតិ ។

## *បង្កើតបណ្តាញជនជាតិដើមភាគតិច និង ពង្រឹងកិច្ចសហប្រតិបត្តិការ*

អ.ជ.ក គឺជាសមាជិកសកម្មរបស់សម្ព័ន្ធជនជាតិដើមភាគតិចនៅកម្ពុជា (CIPA)[3]។ យើងធ្វើការកៀគរ និង បង្កើតបណ្តាញ ជ.ត និង ពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រុមអ្នកពាក់ព័ន្ធផ្សេងៗគ្នាដែលមានគុណតម្លៃ និង បេសកកម្មរួមក្នុងការគាំទ្រសុខុមាលភាពរបស់សង្គម ជ.ត ។ យើងកៀគរសហគមន៍ ជ.ត (ដែលបានបង្កើត និង ចុះបញ្ជី[4]) សកម្មជន ជ.ត និង គណៈកម្មការដឹកនាំ ជ.ត និង ភ្ជាប់ពួកគេជាមួយសម្ព័ន្ធជនជាតិដើមភាគតិចនៅកម្ពុជា (CIPA) ។ យើងគាំទ្រ CIPA បង្កើតនូវយន្តការសម្រាប់ ជ.ត ធ្វើសកម្មភាពនៅមូលដ្ឋាន និង ចែករំលែកព័ត៌មានទៅវិញទៅមកពី មូលដ្ឋានទៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និង អន្តរជាតិ ។

សម្រាប់ការភ្ជាប់ទំនាក់ទំនងនៅថ្នាក់ជាតិ អ.ជ.ក មានឆន្ទៈក្នុងការសម្របសម្រួលបង្កើតឱ្យមានយន្តការថ្នាក់ជាតិសម្រាប់ផ្សារភ្ជាប់ ជ.ត ជាមួយក្រសួងនានា ដើម្បីដាក់បញ្ចូល ជ.ត ក្នុងគ្រប់ការងារអភិវឌ្ឍន៍ ។

## *កសាង និង ពង្រឹងសមត្ថភាពជនជាតិដើមភាគតិច*

អ.ជ.ក កសាង និង ពង្រឹងសមត្ថភាព ជ.ត និង សហគមន៍ ដើម្បីពួកគេមានសមត្ថភាពពេញលេញ និង មានទំនុកចិត្តចូលរួមក្នុងកិច្ចសន្ទនាសង្គម និង សកម្មភាពអភិវឌ្ឍន៍ក៏ដូចជាបម្រើ ជ.ត និង សង្គមកម្ពុជាទាំងមូល ។

អភិក្រមនៃការកសាងសមត្ថភាពរបស់យើងឆ្លើយតបចំពោះតំរូវការផ្សេងៗគ្នារបស់អ្នកដឹកនាំសហគមន៍ សកម្មជន និង ជ.ត នៅក្នុងសហគមន៍ ។

- ការកសាងសមត្ថភាពសម្រាប់អ្នកដឹកនាំសហគមន៍ និង សកម្មជនផ្តោតទៅលើ សិទ្ធិ ជ.ត ការគ្រប់គ្រងដីធ្លី និង ធនធានធម្មជាតិ និង ជំនាញទន់ផ្សេងៗទៀតដូចជា ភាពជាអ្នកដឹកនាំ ការងារគ្រប់គ្រង មូលដ្ឋានច្បាប់ជាតិ និង អន្តរជាតិ (ស្តីអំពីសិទ្ធិ ជ.ត) ជំនាញចរចារ តស៊ូមតិ បង្កើតបណ្តាញ ការគិតឱ្យបានស៊ីជម្រៅ ការធ្វើបទបង្ហាញជាសាធារណៈ ជំនាញសម្របសម្រួល ចងក្រងឯកសារ និង ធ្វើរបាយការណ៍ ។
- ការកសាងសមត្ថភាពសម្រាប់ ជ.ត ផ្តោតទៅលើ សិទ្ធិ និង កាតព្វកិច្ចរបស់ ជ.ត (ដូចជា លើបញ្ហាដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ ការពង្រឹងអភិបាលកិច្ចល្អ និង ការពង្រឹងសេវាសាធារណៈជាដើម) ការចងក្រងសហគមន៍ ការត្រួតពិនិត្យ និង ការអភិវឌ្ឍន៍ជីវភាព និង សេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ។

---

[3] CIPA គឺជាយន្តការគោលសម្រាប់បម្រើ និង ការពារផលប្រយោជន៍ ជ.ត នៅកម្ពុជា ។ CIPA កៀគរសំលេង ជ.ត និង កៀគរអង្គការ ជ.ត ឱ្យចូលរួមធ្វើការងារជាមួយគ្រប់ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា។

[4] ក្នុងឆ្នាំ ២០១៦ មាន បណ្តាញ ជ.ត ចំនួន ១១៩ បានចុះបញ្ជីកំណត់អត្តសញ្ញាណកម្មនៅក្រសួងអភិវឌ្ឍន៍ជនបទ និង បណ្តាញ ជ.ត ចំនួន ១០៥ បានទទួលភាពស្របច្បាប់ពីក្រសួងមហាផ្ទៃ ។

# យុទ្ធសាស្ត្រ ២០១៧ – ២០២០

អ.ជ.ក មានឆន្ទៈមុតមាំក្នុងការលប់បំបាត់ការរំលោភសិទ្ធិ វប្បធម៌ សង្គម និង សេដ្ឋកិច្ចរបស់ ជ.ត និង ការរំលោភយកដីធ្លី និង ធនធានធម្មជាតិនៅក្នុងប្រទេសកម្ពុជា ។ យើងជឿជាក់ថា អភិក្រមគ្រប់ជ្រុងជ្រោយក្នុងការផ្តល់ភាពអង់អាចដល់ ជ.ត ឱ្យគ្រប់គ្រងការអភិវឌ្ឍន៍សហគមន៍ ជ.ត របស់ពួកគេ នឹងនាំឱ្យមានការរីកចំរើន និង សុខុមាលភាពដល់ ជ.ត និង សង្គមកម្ពុជា ។

តាមការវិភាគរបស់យើង (ក្នុងដំណើរការពិនិត្យឡើងវិញលើយុទ្ធសាស្ត្រ) អ.ជ.ក គួរតែបន្តអនុវត្តការរៀនសូត្ររយៈពេលពីរឆ្នាំកន្លងមកនេះនៅក្នុងកម្មវិធីការងាររបស់យើង ។ យើងត្រូវគ្រប់គ្រងការអនុវត្តន៍កម្មវិធីស្នូលរបស់យើងឱ្យឆ្លើយតបទៅតាមតម្រូវការរបស់អ្នកពាក់ព័ន្ធដែលជា ជ.ត ។ យើងក៏ត្រូវបង្កើតកម្មវិធីថ្មីៗបន្ថែមទៀតដើម្បីពង្រីកសេវារបស់យើង និង ឆ្លើយតបយ៉ាងមានប្រសិទ្ធិភាពចំពោះដំណើរការអភិវឌ្ឍន៍ដ៏ស្មុកស្មាញនៅក្នុងប្រទេសកម្ពុជានាពេលអនាគត ។

យើងដាក់ចេញនូវយុទ្ធសាស្ត្រចំនួនបី (ទាក់ទងនឹងកម្មវិធី) សម្រាប់អនុវត្តក្នុងរយៈពេលបួនឆ្នាំខាងមុខ ៖

- គ្រប់គ្រងការអនុវត្តន៍កម្មវិធីស្នូលរបស់អង្គការ ឱ្យឆ្លើយតបទៅតាមតម្រូវការរបស់អ្នកពាក់ព័ន្ធដែលជា ជ.ត
- ធ្វើការតស៊ូមតិ និង ជួយរដ្ឋាភិបាលឱ្យពន្លឿនដំណើរការចុះបញ្ជីដីសហគមន៍
- ពង្រឹងជីវភាព និង សកម្មភាពសេដ្ឋកិច្ចរបស់សហគមន៍ ជ.ត

ការវិភាគផ្ទៃក្នុងរបស់យើង លើចំនុចខ្លាំង ចំនុចខ្សោយ ឱកាស និង ការគំរាមកំហែង (ឧបសម្ព័ន្ធទី ២) បានតម្រូវឱ្យយើងបន្តធ្វើការពង្រឹងសមត្ថភាពរបស់អង្គការ ដើម្បីអាចបំពេញប្រតិបត្តិការកាន់តែមានប្រសិទ្ធភាព និងទទួលបាននូវផលប៉ះពាល់ជាអតិបរិមា ។ អាទិភាពរបស់យើងគឺធ្វើការបង្កើនសមត្ថភាពបុគ្គលិក និង កៀគរថវិការសម្រាប់អនុវត្តកម្មវិធីការងារ។ ដូច្នេះ យើងដាក់ចេញនូវយុទ្ធសាស្ត្រចំនួនពីរ (ដើម្បីអភិវឌ្ឍអង្គការ) រួមមាន ៖

- ពង្រឹងសមត្ថភាពរបស់អង្គការ ដើម្បីប្រតិបត្តិការការងារប្រកបដោយគុណភាព និង មានប្រសិទ្ធភាពខ្ពស់
- ស្វែងរកធនធានគាំទ្រកម្មវិធីការងារ និង ដំណើរការរបស់អង្គការ

## យុទ្ធសាស្ត្រទី ១ ៖ គ្រប់គ្រងការអនុវត្តន៍កម្មវិធីស្នូលរបស់អង្គការ ឱ្យឆ្លើយតបទៅតាមតម្រូវការរបស់អ្នកពាក់ព័ន្ធដែលជាជនជាតិដើមភាគតិច

ការអភិវឌ្ឍន៍នៅកម្ពុជាមានលក្ខណៈស្មុកស្មាញដែលបញ្ហាជាច្រើនជាប់ទាក់ទង និង មានឥទ្ធិពលលើគ្នាទៅវិញទៅមក ។ ជាការសំខាន់ដែលយើងត្រូវវិភាគរកឬសគល់របស់បញ្ហា និង កំណត់មុខសញ្ញាសំខាន់ៗដែលមានឥទ្ធិពលលើការផ្លាស់ប្តូរ ។ យើងត្រូវយល់អំពីបញ្ហាឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីធ្វើការកំណត់អ្វីជាការពិត ។

ជាដំបូងយើងត្រូវធ្វើការកំណត់ឱ្យបានច្បាស់លាស់អំពីវិស័យដែលត្រូវធ្វើការអភិវឌ្ឍន៍ និង បញ្ហាដែលត្រូវជាមួយនឹងបទពិសោធន៍ និង ជំនាញរបស់យើង ដើម្បីលើកជាផែនការ និង អនុវត្តកម្មវិធីការងារដែលបង្កើតឱ្យមានការផ្លាស់ប្តូរជាសំខាន់ និង ជានិរន្ត ។

យើងត្រូវដាក់ចេញនូវគោលការណ៍ និង វិធីសាស្ត្រស្នូល[5] ដើម្បីតម្រង់ទិសដល់ការធ្វើផែនការកម្មវិធីការងាររបស់យើង ។ តាមរយៈគោលការណ៍នេះ គ្រប់ដំណើរការកសាងផែនការត្រូវចាប់ផ្តើមពីចំនុចដែលមានប្រសិទ្ធភាពដើម្បីធ្វើជាមូលដ្ឋានឆ្លើយតបទៅតាមតម្រូវការរបស់អ្នកពាក់ព័ន្ធដែលជា ជ.ត ។ គុណសម្បត្តិរបស់វាគឺទី ១ បុគ្គលិកយល់ពីគោលគំនិតរួមរបស់កម្មវិធីនីមួយៗ និង អាចយកវាទៅអនុវត្តនៅក្នុងបរិបទថ្មីៗទៀត ។ ទី ២ គឺផែនការនីមួយៗអាចសម្រេចបានយ៉ាងមានប្រសិទ្ធផលដោយសារតែវាមិនចាំបាច់ចាប់ផ្តើមពីដំបូងឡើងវិញ ។

កិច្ចការនេះតម្រូវឱ្យបង្កើតជាមគ្គុទ្ទេសដែលកំណត់គោលការណ៍ស្នូល វិធីសាស្ត្រ និង ផលប្រយោជន៍ដែលអាចយកមកប្រើប្រាស់ធ្វើជាចំនុចចាប់ផ្តើមបង្កើតគម្រោងសំណើរ និង កម្មវិធីការងារ ។ ធ្វើការជាមួយនឹងគោលការណ៍ និង វិធីសាស្ត្រទាំងអស់នោះ អ.ជ.ក នឹងអាចបំពេញការងារឆ្លើយតបទៅតាមតម្រូវការរបស់ ក្រុមគោលដៅ និង ដៃគូរទាំងអស់ ។

## យុទ្ធសាស្ត្រទី ២ ៖ ការតស៊ូមតិ និង ជួយរដ្ឋាភិបាលឱ្យពន្លឿនដំណើរការចុះបញ្ជីដីសហគមន៍[6]

ការវិភាគរបស់យើងលើបរិបទអភិវឌ្ឍន៍នៅកម្ពុជា (ឧបសម្ព័ន្ធទី ១) បង្ហាញអំពីអប្រសិទ្ធភាពរបស់រដ្ឋាភិបាលក្នុងការអនុវត្តន៍អនុក្រឹតស្តីពីការចុះបញ្ជីដីសហគមន៍ ជ.ត និង វិធានការអន្តរកាលដើម្បីទប់ស្កាត់ការបាត់បង់ដីរបស់ ជ.ត បន្ថែមទៀតនៅខណៈដែលការចុះបញ្ជីដីសមូហភាពកំពុងដំណើរការ ។.

អ.ជ.ក នឹងធ្វើការជាមួយសហគមន៍ ជ.ត នាយកដ្ឋានពាក់ព័ន្ធរបស់សដ្ឋាភិបាល និង សង្គមស៊ីវិលដើម្បីកំណត់វិធានការ និង យន្តការសមស្របដើម្បីបង្កើនល្បឿននៃដំណើរការចុះបញ្ជីដីសហគមន៍របស់ ជ.ត ជាពិសេសបង្កើនល្បឿនក្នុងការធ្វើស្វ័យអត្តសញ្ញាណ និង គូរផែនទីសហគមន៍ ។ យើងនឹងកត់ត្រានូវករណី ឬបញ្ហាផ្សេងៗដែល

[5] គោលការណ៍គឺជាគំរូ ឬការសន្មត់ (ទុកជាមុន) ដែលរៀបរាប់អំពីឬសគល់នៃបញ្ហា ។ វិធីសាស្ត្រគឺជារបៀបនៃការអនុវត្តន៍គោលគារណ៍ដើម្បីបង្កើតការផ្លាស់ប្តូរជាវិជ្ជមាន ដូចបានព្យាករណ៍ទុកស្រាប់ ។ កម្មវិធីគាំទ្រ និង អភិវឌ្ឍអ្នកដឹកនាំ ជ.ត របស់យើង គឺផ្អែកតាមគោលការណ៍ដែលថាមនុស្សមានសក្តានុពលក្នុងការអភិវឌ្ឍន៍ កំណត់នូវគោលដៅរបស់ពួកគេ ឬដឹកនាំអ្នកដ៏ទៃដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរចំពោះខ្លួនគេ និង ចំពោះសហគមន៍របស់គេ ។ ដូច្នេះវិធីសាស្ត្ររបស់យើងគឺផ្តោតទៅលើការផ្តល់ភាពអង់អាចដល់មនុស្សឱ្យមានការជឿជាក់លើខ្លួនឯងមានឆន្ទះ ចូលរួម និង ហ៊ានប្រឈមជាមួយហានិភ័យដើម្បីអនុវត្តកិច្ចការថ្មីៗ ។

[6] ឧបសម្ព័ន្ធទី ២ ៖ ជំហានទាំង ២៩ សម្រាប់ចុះបញ្ជីដីសហគមន៍

បណ្តាលឱ្យ ជ.ត មិនអាចដាក់សំណើរសុំចុះបញ្ជីដីសហគមន៍បាន ។ បន្ទាប់មកយើងនឹងធ្វើការកៀគរធនធាន និង ផ្តល់ការគាំទ្របច្ចេកទេសទៅដល់សហគមន៍ ជ.ត ដើម្បីពិភាក្សាជាមួយភ្នាក់ងាររដ្ឋាភិបាលទាំងអស់ ឱ្យដោះស្រាយបញ្ហាជុំវិញការចុះបញ្ជីដីសហគមន៍ទាំងអស់នោះ ។

យើងនឹងសម្របសម្រួលសមាជិកសហគមន៍ឱ្យធ្វើការពិនិត្យ និង កំណត់ឡើងវិញនូវគណកម្មការចុះបញ្ជីដីសហគមន៍[7] ដោយរក្សាទុកតែអ្នកដែលមានឆន្ទះ និង សកម្មធ្វើជាដំណាង ជ.ត ពិតប្រាកដ ។ ដំណើរការត្រួតពិនិត្យ និង កំណត់ឡើងវិញវគណកម្មការចុះបញ្ជីដីសហគមន៍នេះនឹងធ្វើរៀងរាល់មួយឆ្នាំម្តង ។

យើងនឹងធ្វើការពង្រឹងសមត្ថភាពគណកម្មការចុះបញ្ជីដីសហគមន៍ ដើម្បីពួកគេអាចជួយដឹកនាំសហគមន៍ឱ្យទទួលបានការចុះបញ្ជីដីសហគមន៍ ។ ការពង្រឹងសមត្ថភាពនឹងផ្តោតទៅលើ ភាពជាអ្នកដឹកនាំ ការគ្រប់គ្រងច្បាប់ដីធ្លី ការដោះស្រាយវិវាទ និង អភិក្រមអភិវឌ្ឍន៍ ដែលអាចជួយពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ពួកគេក្នុង នាមជាអ្នកដឹកនាំ និង ជាដំណាងរបស់សហគមន៍ ជ.ត ។

យើងនឹងផ្សារភ្ជាប់សហគមន៍ជាមួយនឹងបណ្តាញផ្សេងៗដូចជា ក្រុមផ្តល់ភាពអង់អាច និង អភិវឌ្ឍសហគមន៍ (ដែលមានជំនាញឯកទេសផលិតផែនទីដីសហគមន៍) សម្ព័ន្ធ ជ.ត កម្ពុជា (ដែលជាអង្គការបណ្តាញ) និង យន្តការផ្សេងៗទៀត ដើម្បីចូលរួមចំណែកការពារដីធ្លីរបស់ ជ.ត និង ធ្វើការតស៊ូមតិដើម្បីបង្កើនល្បឿនដំណើរការចុះបញ្ជីដីសហគមន៍ ។

## យុទ្ធសាស្រ្តទី ៣ ៖ ពង្រឹងជីវភាព និង សកម្មភាពសេដ្ឋកិច្ចរបស់សហគមន៍ ជ.ត

គោលនយោបាយរបស់រដ្ឋាភិបាលជម្រុញឯកជនភាវូនីយ៍កម្ម បានបង្កឱ្យមានផលប៉ះពាល់ជាអវិជ្ជមាន ដូចជាការរំលោភយកដីធ្លីពីបណ្តាក្រុមហ៊ុនមួយចំនួនដើម្បីពង្រីកកសិឧស្សាហ៍កម្ម (ឧ. ធ្វើចំការដំណាំកៅស៊ូ និង អំពៅជាដើម) និង អាជីវកម្មរ៉ែ របស់ពួកគេ ។ ការរីកចម្រើនរបស់ក្រុមហ៊ុនឯកជនបានផ្លាស់ប្តូរទម្លាប់រស់នៅនិងប្រពៃណីយ៍ ធ្វើកសិកម្មរបស់សហគមន៍ ជ.ត ។ មានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សពីដីកម្មសិទ្ធិរួមទៅ ជាកម្មសិទ្ធិឯកជនមាន ជំលោះដីធ្លីយ៉ាងខ្លាំងក្លា (រវាងក្រុមហ៊ុន រដ្ឋាភិបាល និង ប្រជាពលរដ្ឋ) មានការបង្ខិតបង្ខំ ឱ្យផ្លាស់ប្តូរទីលំនៅ និង ការបាត់បង់ដីធ្លី ។ ទាំងអស់នេះបានក្លាយជាសម្ពាធយ៉ាងខ្លាំងដល់ ជ.ត ជាពិសេសគឺប៉ះពាល់ ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ ។

អ.ជ.ក នឹងសម្របសម្រួល ជ.ត ស្វែងរកនូវវិធីសាស្រ្តផ្សេងៗដើម្បីបង្កើនជីវភាពនិង សេដ្ឋកិច្ចរបស់សហគមន៍ ជ.ត ប្រកបដោយនិរន្តរភាព ។ យុទ្ធសាស្រ្តនេះនឹងផ្តោតទៅលើ ៖

- ធ្វើការពិនិត្យឡើងវិញចំពោះគ្រួសារ ជ.ត ដែលក្រីក្រ និង ត្រូវការជំនួយខ្លាំងបំផុត ។ សម្របសម្រួលដំណើរការចងក្រងពួកគេឱ្យក្លាយជាក្រុមជួយខ្លួនឯង (ផ្អែកតាមចំណាប់អារម្មណ៍របស់ពួកគេ) ហើយធ្វើការ

[7] តាមការពិនិត្យរបស់យើងសមាជិកមួយចំនួនរបស់គណៈកម្មការពុំសូវសកម្មក្នុងការអនុវត្តន៍តួនាទីរបស់ខ្លួនក្នុងការធ្វើជាដំណាង និងតស៊ូមតិតដើម្បីផលប្រយោជន៍របស់ ជ.ត ។

ជ្រើសរើសជនបង្គោល[8]ប្រចាំភូមិនីមួយៗ ។ យើងនឹងផ្តល់ជំនួយបច្ចេកទេស និង សម្របសម្រួលពួកគេជាមួយក្រុមប្រឹក្សាឃុំ ដើម្បីអាចដាក់បញ្ចូលបញ្ហារបស់ពួកគេទៅក្នុងផែនការវិនិយោគឃុំ ។

- បង្កើនសមត្ថភាព ជ.ត លើការប្រើប្រាស់ដីធ្លី កសិកម្មសមស្រប សិប្បកម្មប្រពៃណីយ៍ និង ការធ្វើផែនការ និង ដំណើរការអាជីវកម្ម ដើម្បីពួកគេអាចប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធិភាពសម្រាប់បង្កើន និង ធានានិរន្តរភាពជីវភាពរបស់ពួកគេ ។
- គាំទ្រការផ្តួចផ្តើមគំនិតអាជីវកម្មដោយផ្អែកលើចំណេះដឹងជាប្រពៃណីយ៍ ជំនាញ និង បទពិសោធន៍របស់ ជ.ត ឧ. ជាអ្នកផលិត និង លក់ផលិតផលកសិកម្ម និង មិនមែនកសិកម្ម[9] និង អាជីវកម្មផ្សេងៗដូចជា លក់ចាប់ហួយនៅក្នុងភូមិ បង្កើតតំបន់ទេសចរធម្មជាតិ និង បើកហាងលក់កាហ្វេ និង វត្ថុអនុស្សាវរីយ៍ (នៅទីរួមខេត្ត និង តំបន់ទេសចរធម្មជាតិ) ។ បង្កើតផ្សារ ឬ កន្លែងលក់ដុំ នៅក្នុឃុំ ផ្សារស្រុក ឬផ្សារខេត្ត សម្រាប់លក់ និង ផ្សព្វផ្សាយផលិតផលរបស់ ជ.ត ។

អ.ជ.ក មានបទពីសោធន៍ច្រើនក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍ចំរុះសម្រាប់ ជ.ត នៅកម្ពុជា ។ ទោះជាយ៉ាងណាក៏ដោយ នៅមានអង្គការជាច្រើនទៀតដែលបានអនុវត្តកម្មវិធីប្រហាក់ប្រហែលនឹង អ.ជ.ក ដែរដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍ ជ.ត ។ ដូច្នេះ អ.ជ.ក នឹងពិនិត្យមើលឱកាសសមស្របដើម្បីសហការជាមួយអង្គការទាំងអស់នោះធ្វើការចែករំលែកគំរូល្អៗក្នុងការអភិវឌ្ឍន៍សហគមន៍ចំរុះ និង ដែលបង្កើតផលប៉ះពាល់ជាវិជ្ជមានដល់សហគមន៍ ។

## យុទ្ធសាស្រ្តទី ៤ ៖ ពង្រឹងសមត្ថភាពរបស់អង្គការ ដើម្បីប្រតិបត្តិការការងារប្រកបដោយគុណភាពនិង មានប្រសិទ្ធភាពខ្ពស់

អ.ជ.ក មានកេរ្តិ៍ឈ្មោះល្អក្នុងការអនុវត្តន៍ការងាររបស់យើង ។ យើងប្រតិបត្តិការងារនៅក្នុងបរិយាកាសមួយដែលស្មុគស្មាញ និង មានការផ្លាស់ប្តូរខ្លាំង ដែលតម្រូវឱ្យយើងត្រូវមានភាពបត់បែន បន្សាំខ្លួនជាមួយនឹងបរិយាកាសនិង មានប្រសិទ្ធិភាពការងារខ្ពស់ ។ យើងត្រូវប្រើប្រាស់ថវិការរបស់យើងឱ្យកាន់តែមានប្រសិទ្ធិភាព និង ទទួលបាន លទ្ធផលការងារល្អ។ យើងត្រូវតែមានភាពបត់បែន និង ធានាប្រសិទ្ធិផលខ្ពស់ចំពោះ ប្រតិបត្តិការរបស់យើង ។ ដូច្នេះយើងត្រូវពង្រឹងអង្គការរបស់យើងដើម្បីឆ្លើយតបទៅតាមតម្រូវការរបស់ម្ចាស់ មូលនិធិ និង ដើម្បីឆ្លើយតប យ៉ាងមានប្រសិទ្ធិភាពចំពោះតម្រូវការរបស់សហគមន៍។ កិច្ចការនេះតម្រូវឱ្យអ.ជ.ក ធ្វើការពិនិត្យឡើងវិញយ៉ាង ទៀងទាត់លើរចនាសម្ព័ន្ធ ប្រព័ន្ធ និតិវិធី គោលនយោបាយ និង សមត្ថភាពបុគ្គលិក ដើម្បីធានាថា អ.ជ.ក ប្រតិបត្តិការងារបង្កើតបាននូវលទ្ធផល និង ផលប៉ះពាល់ ឆ្លើយតបជាមួយនឹងយុទ្ធសាស្រ្ត របស់អង្គការ ។

[8] ការជ្រើសរើសជនបង្គោលគឺផ្អែកលើកំរិតវប្បធម៌ (យ៉ាងហោចណាស់ចប់មធ្យមសិក្សា) និង ឆន្ទះរបស់គេក្នុងការជួយ ជ.ត នៅក្នុភូមិ ។ ជនបង្គោលមានតួនាទីសំខាន់សម្រាប់ផ្សារភ្ជាប់ ជ.ត ជាមួយក្រុមប្រឹក្សាឃុំ និង បណ្តាញផ្សេងៗដូចជា CIPA ។ ជនបង្គោលនឹងធ្វើការកសាងសមត្ថភាពដល់ ជ.ត និង គាំទ្រ ក្រុមជួយខ្លួនឯងឱ្យធ្វើផែនការ និង គ្រប់គ្រងឱកាសអាជីវកម្មនៅក្នុងឃុំ ។

[9] ផលិតផលកសិកម្មរួមមាន ឧ. ផ្លែឈើ និង បន្លែ មាន់ ទា និង សត្វពាហនៈ ។ ផលិតផលមិនមែនកសិកម្មរួមមានអនុផលព្រៃឈើ និង សិប្បកម្ម.

## យុទ្ធសាស្ត្រទី ៥ ៖ ស្វែងរកធនធានគាំទ្រកម្មវិធីការងារ និង ដំណើរការរបស់អង្គការ

ដូចអង្គការផ្សេងៗទៀតដែរ អ.ជ.ក ពឹងផ្អែកលើម្ចាស់ជំនួយទាំងក្នុងស្រុក និង អន្តរជាតិ ។ ស្ថានការណ៍សេដ្ឋកិច្ចជាសកលមានភាពពុំនឹងនរ ហើយការធ្លាក់ចុះនៃសេដ្ឋកិច្ចនៅឆ្នាំខាងមុខនឹងប៉ះពាល់ដល់ជំនួយមកប្រទេសកម្ពុជា ។ ម្ចាស់មូលនិធិកាត់បន្ថយថវិការ ហើយម្ចាស់មូលនិធិមួយចំនួនបានបង្វែរថវិការទៅប្រទេសផ្សេង ។ ក្នុងពេលជាមួយគ្នានេះដែរថវិការភាគច្រើនត្រូវបង្វែរទៅឱ្យរដ្ឋាភិបាល និង សហគមន៍មូលដ្ឋានដោយផ្ទាល់ ។ ទាំងអស់នេះមានន័យថាយើងត្រូវធ្វើការប្រកួតប្រជែងជាមួយអង្គការផ្សេងៗទៀតដើម្បីបានថវិការមកអនុវត្តការងារ ។

យើងត្រូវខិតខំស្វែងរកប្រភពថវិការថ្មីៗបន្ថែមទៀត ជាពិសេសថវិការសម្រាប់គម្រោងរយៈពេលវែងដើម្បីធានានិរន្តរភាពប្រតិបត្តិការរបស់យើង ។ យើងក៏ត្រូវពិចារណាផងដែរក្នុងការស្វែងរកថវិការពីផ្នែកឯកជន រដ្ឋាភិបាល និងពីសហគមន៍ ។

យើងត្រូវផ្តោតអាទិភាពទៅលើការប្រាស្រ័យទាក់ទង និង បង្ហាញអំពីផលប្រយោជន៍នៃសេវាកម្មរបស់យើងទៅដល់ម្ចាស់ជំនួយ និង សហគមន៍គោលដៅ ។ ដូច្នេះ យើងត្រូវធ្វើការកំណត់អំពីផលប្រយោជន៍ដែលសេវាកម្មរបស់យើងផ្តល់ទៅឱ្យសមាជិកសហគមន៍ ។ យើងត្រូវធ្វើការបង្ហាញឱ្យបានច្បាស់លាស់ និង មានលក្ខណសាមញ្ញដូចជា តើកម្មវិធីរបស់យើងនឹងផ្តល់លទ្ធផល និងផលប៉ះពាល់ជាវិជ្ជមានអ្វីខ្លះដល់សហគមន៍ ជ.ត ។ យើងត្រូវធានាថា បុគ្គលិកទាំងអស់បានយល់ដូចៗគ្នាអំពីសារដែលត្រូវផ្សព្វផ្សាយនោះ ដើម្បីពួកគេយកទៅផ្សព្វផ្សាយឱ្យបានទូលំទូលាយក្នុងនាម អ.ជ.ក ។ យើងត្រូវរៀបចំឱ្យមានកិច្ចប្រជុំទៀងទាត់ជាមួយម្ចាស់ជំនួយ អង្គការ ជ.តនិងសហគមន៍ មូលដ្ឋាន ដើម្បីធ្វើបច្ចុប្បន្នភាព និង រៀនពីគ្នាទៅវិញទៅមក និងស្វែងយល់ពីវិធីដ៏ប្រសើរមួយសម្រាប់ម្ចាស់មូលនិធិផ្ទេរថវិការមកគាំទ្រ ជ.ត ។

អាទិភាពចុងក្រោយរបស់យើងគឺ
ស្វែងរកលទ្ធភាពក្នុងការបង្កើតចំណូលដើម្បីបំពេញនូវកង្វះខាតថវិការពីម្ចាស់ជំនួយ។
ចំនុចមួយដែលយើងគួរពិចារណារគឺ ធ្វើការពិនិត្យឡើងវិញនូវសកម្មភាពមួយចំនួនរបស់យើង (ឧទាហរណ៍ ៖ សេវាកម្មពស្តុភារ និង សម្របសម្រួល) អាចបង្កើតប្រាក់ចំណូលដល់អង្គការ តាមរយៈការគិតថ្លៃ សេវាកម្មពីម្ចាស់ជំនួយ អង្គការផ្សេងៗ អាជ្ញាធរមូលដ្ឋាន និង នាយកដ្ឋានរបស់រដ្ឋាភិបាល ដែលបានប្រើប្រាស់សេវារបស់យើង ។

# គោលបំណងយុទ្ធសាស្ត្រ សូចនាករ មធ្យោបាយវាស់វែង និង លទ្ធផលចំបងៗ

គោលបំណងយុទ្ធសាស្ត្រ សូចនាករមធ្យោបាយវាស់វែង និង លទ្ធផលចំបងៗ បានកំណត់សម្រាប់យុទ្ធសាស្ត្រនីមួយៗ សម្រាប់ជាមូលដ្ឋានក្នុងការធ្វើផែនការ ត្រួតពិនិត្យ វាយតម្លៃ និង របាយការណ៍លទ្ធផលប្រចាំឆ្នាំ ។

| យុទ្ធសាស្ត្រទី ១ ៖ គ្រប់គ្រងការអនុវត្តន៍កម្មវិធីស្នូលរបស់អង្គការឱ្យឆ្លើយតបទៅតាមតម្រូវការរបស់អ្នកពាក់ព័ន្ធដែលជាជនជាតិដើមភាគតិច | | | | | | | |
|---|---|---|---|---|---|---|---|
| ការប៉ាន់ប្រមាណ | គោលបំណង | សូចនាករ | មធ្យោបាយវាស់វែង | លទ្ធផលចំបងៗ | | | |
| | | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
| • មិនទាន់មានរបាយការណ៍ជាតិស្តីពីទិន្នន័យជនជាតិដើមភាគតិច<br>• មានទិន្នន័យមួយចំនួនដែលមានមានពត៌មានមិនទាន់ស៊ីគ្នារវាងក្រសួងផែនការ និងក្រសួងអភិវឌ្ឍន៏ជនបទ | 1.1 បានបង្កើតមជ្ឈមណ្ឌលជនជាតិដើមភាគតិច<br>- រដ្ឋាភិបាល និង សហគមន៍ ជ.ត មានមោទនភាពចំពោះពហុវប្បធម៌ របស់សង្គមកម្ពុជា<br>- វប្បធម៌ និង ប្រពៃណី ជ.ត ត្រូវបាន | 1.1.1 បោះពុម្ពផ្សាយ របាយការណ៍ជំរឿន ជ.ត និង បង្កើតទិន្នន័យ មូលដ្ឋាន ជ.ត | - កំណត់ត្រា និង ទិន្នន័យមូលដ្ឋាន ជ.ត<br>- របាយការណ៍ជំរឿន ជ.ត<br>- ឯកសារគោលជំហរ<br>- កំណត់ហេតុ និង របាយការណ៍ប្រជុំ និង សិក្ខាសាលា<br>- កិច្ចព្រមព្រៀង និង អនុសារណៈដែគូរ | - បញ្ចប់ការធ្វើផែនទីទិន្នន័យចំបងៗរបស់ ជ.ត និង បញ្ចូលក្នុងគេហទំព័រ របស់ ODC/ CIPO/ ADIC<br>- ដាក់សំណើរសង្ខេបគោលនយោបាយ (ទៅក្រសួងពាក់ព័ន្ធ ដៃគូរអភិវឌ្ឍន៍ ភ្នាក់ងារអង្គការសហប្រជា ជាតិ និង អ្នកពាក់ព័ន្ធទាំង អស់) ដើម្បីធ្វើការតស៊ូមតិជាមួយរដ្ឋាភិបាលឱ្យលើកផែនការ និង ដាក់បញ្ចូលជំរឿន ជ.ត ទៅក្នុងជំរឿនថ្នាក់ជាតិ ឆ្នាំ ២០១៩ ។ | – ធ្វើផែនទីទិន្នន័យ ជ.ត ឆ្នាំ ២០០៨ និង បញ្ចូលក្នុងគេហទំព័រ របស់ ODC/CIPO/AIDC<br>– កៀគរធនធានដើម្បី គាំទ្រ ជ.ត និង អ្នកពាក់ព័ន្ធឱ្យចូលរួមក្នុង ដំណើរការធ្វើទិន្ន | – កៀគរ ជ.ត និង អ្នកពាក់ព័ន្ធឱ្យចូលរួមក្នុងដំណើរការធ្វើទិន្នន័យប្រជាជន<br>– គាំទ្រ និង ចូលរួមត្រួតពិនិត្យរដ្ឋាភិបាលធ្វើជំរឿនប្រជាជន<br>– ផលិតរបាយការណ៍ជំរឿន ជ.ត ឆ្នាំ ២០១៩ និង ដាក់ឱ្យប្រើប្រាស់ | - ផ្សព្វផ្សាយរបាយការណ៍ទៅដល់អ្នកពាក់ព័ន្ធ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | កត់ត្រា និង<br>ផ្សព្វផ្សាយ<br>យ៉ាងទូលំ<br>ទូលាយ | | | | - ធ្វើការជាមួយក្រសួង<br>អភិវឌ្ឍន៍ជនបទ និងក្រសួង<br>ផែនការ និង អ្នកពាក់ព័ន្ធ<br>ដើម្បីផលិតរបាយការណ៍ទិន្នន័<br>យជ.ត ឆ្នាំ ២០០៨ និង ឆ្នាំ<br>២០១៩<br>- ផលិតរបាយការណ៍ទិន្នន័យ<br>ជ.ត ឆ្នាំ ២០០៨<br>- ផ្តល់តារាងឈ្មោះជន បង្គោល<br>ជ.ត សម្រាប់ផ្តល់<br>យោបល់ក្នុងការបង្កើតកំរ៉ង<br>សំណួរ និង<br>ចូលរួមក្នុងការធ្វើជំរឿន ជ.ត | ន័យ ប្រជាជនឆ្នាំ<br>២០១៩ | | |
| • មិនទាន់មានសារ<br>មន្ទីរជនជាតិដើម<br>ភាគតិច<br>ប៉ុន្តែមានមជ្ឈម<br>ណ្ឌលវប្បធម៌ជន<br>ជាតិដើមភាគតិច<br>មួយនៅ | | 1.1.2 | បង្កើតសារ<br>មន្ទីរជនជាតិ<br>ដើម<br>ភាគតិច | - ផែនការគោលឬ<br>មេ<br>- តារាងឈ្មោះអ្នក<br>គាំទ្រ<br>(រដ្ឋាភិបាល<br>អង្គការក្រៅ<br>រដ្ឋាភិបាល ដៃគូរ | - ធ្វើតារាងឈ្មោះអ្នកគាំទ្រ<br>ធនធាន<br>- កៀរធនធានដើម្បីធ្វើ<br>ផែនការគោល<br>- ធ្វើការជាមួយទី ប្រឹក្សា<br>ក្រសួងអភិវឌ្ឍន៍ជនបទ<br>និងក្រសួងវប្បធម៌ ដើម្បីធ្វើ | - ធ្វើបច្ចុប្បន្នភាព<br>តារាងឈ្មោះអ្នក<br>គាំទ្រ ធនធាន<br>- ពិភាក្សាពង្រាង<br>ផែនការគោលជា<br>មួយ រដ្ឋាភិបាល<br>និង អ្នកពាក់ព័ន្ធ | - ធ្វើបច្ចុប្បន្នភាព<br>តារាងឈ្មោះអ្នកគាំ<br>ទ្រធនធាន<br>- បន្តបញ្ចប់ផែនការ<br>គោល<br>– កៀរធនធានដើម្បី<br>កសាងសារមន្ទីរជ.ត | - កសាង និង<br>ដាក់ឱ្យ<br>ប្រើប្រាស់សា<br>រមន្ទីរ ជ.ត<br>- ធ្វើបច្ចុប្បន្នភា<br>ព<br>តារាងឈ្មោះ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខេត្តរតនគិរី | | | | អភិវឌ្ឍន៍ ភ្នាក់ងារអង្គការសហប្រជាជាតិ)<br>- កំណត់ហេតុ និង របាយការណ៍ ប្រជុំ និង សិក្ខាសាលា | ពង្រាងផែនការគោលសម្រាប់កសាងសារមន្ទីរ<br>- ចងក្រងឯកសារ ជ.ត ឧបករណ៍ និង សម្ភារៈ | - គៀរធនធានដើម្បី កសាងសារមន្ទីរ ជ.ត<br>- ចងក្រងឯកសារ ជ.ត ឧបករណ៍ និង សម្ភារៈ | – បន្តចងក្រងឯកសារ ជ.ត ឧបករណ៍ និង សម្ភារៈ | អ្នកគាំទ្រធនធាន<br>- បន្តគៀរធនធានដើម្បីគាំទ្រប្រតិបត្តិការ សារមន្ទីរ ជ.ត<br>- បន្តចងក្រងឯកសារ ជ.ត ឧបករណ៍ និង សម្ភារៈ |
| • នៅមិនទាន់មានការសិក្សាប៉ាន់ប្រមាណពីសារៈសំខាន់នៃតម្រូវការអ្នកដឹកនាំជនជាតិដើមភាគតិចនៅឡើយទេ<br>• ២០១៥ និង២០១៦ អ.យ.ក | 1.2 បានគាំទ្រ និងអភិវឌ្ឍអ្នកដឹកនាំជនជាតិដើមភាគតិច | 1.2.1 | ដំណើរការកម្មវិធីហាត់រៀន របៀបដឹកនាំ និង គ្រប់គ្រងជារៀងរាល់ឆ្នាំ | - ឯកសារកម្មវិធីឬក្របខណ្ឌការងារហាត់រៀន<br>- ពាក្យសុំចូលហាត់រៀន<br>- កិច្ចសន្យាហាត់រៀន និង របាយការណ៍វាយតម្លៃ | - ជ្រើសរើស ជ.ត ៦ នាក់ (ស្រី ៤នាក់) ដើម្បីធ្វើការកសាងសមត្ថភាព ។ បីនាក់រៀននៅ អ.ជ.ក និង បីនាក់ទៀតរៀននៅអង្គការផ្សេង ។<br>- ផ្តល់ការណែនាំ និង បច្ចេកទេសដល់អ្នកហាត់រៀន ដើម្បីសរសេរគម្រោង សំណើរ (ដាក់ជូន អ.ជ.ក និង ម្ចាស់ជំនួយ) និង អនុវត្ត | - ដូចឆ្នាំ ២០១៧<br>- ធ្វើការឆ្លុះបញ្ចាំង និង កត់ត្រាការរៀនសូត្រ | - ដូចឆ្នាំ ២០១៨<br>- ធ្វើការឆ្លុះបញ្ចាំង និង កត់ត្រាការរៀនសូត្រ | - ដូចឆ្នាំ ២០១៩<br>- វាយតម្លៃ និង ផ្តល់អនុសាសន៍ សម្រាប់ធ្វើផែនការអនាគត |

| | | | | | | | |
|---|---|---|---|---|---|---|---|
| បានគាំទ្រជួយកម្មសិក្សាការីជនជាតិដើមចំនួន៤រូប<br>• មានអ្នកដឹកនាំជាជនជាតិដើមភាគតិចគឺសំខាន់ណាស់ដើម្បីធ្វើការជួយដល់ជនជាតិដើមភាគតិចខ្លួនឯង | | | | គម្រោងរបស់ពួកគេ ។<br>- រៀបចំធ្វើការសិក្សាប៉ាន់ប្រមាណពីតម្រូវការភាពជាអ្នកដឹកនាំ | | | |
| • នៅមិនទាន់មានកម្មវិធីសម្រាប់ផ្តល់រង្វាន់លើកទឹកចិត្តដល់ជនជាតិដើមភាគតិចនៅក្នុងប្រទេស ប៉ុន្តែកន្លងទៅមានអ្នកដឹកនាំស្ត្រីជនជាតិដើមភាគតិចម្នាក់ ដែលជាប្រធានស្ថាប័នអង្គការខ្មែរ | 1.2.2 | ចំនួនសកម្មជន ក្នុងសហគមន៍ កើនឡើងជារៀងរាល់ឆ្នាំ ដោយ មានយ៉ាង ហោចណាស់ចំនួន ១៥ នាក់ | - កំណត់ហេតុប្រជុំគណៈគ្រប់គ្រងអង្គការ<br>- របាយការណ៍កម្មវិធីប្រចាំឆ្នាំ<br>- តារាងឈ្មោះសកម្មជន | - បង្កើតលក្ខណៈវិនិច្ឆ័យ និងដំណើរការជ្រើសរើសសកម្មជនជាមួយ CIPA<br>- គៀងគរមូលនិធិដើម្បីគាំទ្រដំណើរការជ្រើសរើសសកម្មជន<br>- រៀបចំព្រឹត្តិការណ៍ផ្តល់រង្វាន់ប្រចាំឆ្នាំដល់សកម្មជនជាសាធារណៈ<br>- ផ្តល់ការគាំទ្រជាប្រចាំ និងកសាងសមត្ថភាពដល់សកម្មជន ១៥ នាក់ ដែល | - ដូចឆ្នាំ ២០១៧<br>- ធ្វើការឆ្លុះបញ្ចាំង និង កត់ត្រាការរៀនសូត្រ | - ដូចឆ្នាំ ២០១៨<br>- ធ្វើការឆ្លុះបញ្ចាំង និង កត់ត្រាការរៀនសូត្រ | - ដូចឆ្នាំ ២០១៩<br>- វាយតម្លៃ និងផ្តល់អនុសាសន៍ សម្រាប់ធ្វើផែនការអនាគត |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| លើបានរង្វាន់ពីខាងក្រៅប្រទេស។<br>• មានបណ្ដាញផ្សេងៗមួយចំនួនដូចជា (អាយវ៉ាម សេសានដែលជាជនជាតិដើមភាគតិច) ប៉ុន្តែពួកគេនៅមិនទាន់បានប្រមូលផ្ដុំជាបណ្ដាញផ្លូវការនៅឡើយ<br>• មានសម្ព័ន្ធជនជាតិដើមភាគតិច ប៉ុន្តែមិនទាន់ផ្លូវការ ទោះបីជាយ៉ាងណាយើងបានបង្កើត និងចងក្រងគ្នាទៅវិញទៅមកក្នុងដំ | 1.3 បានបង្កើតបណ្ដាញជនជាតិដើមភាគតិច និងពង្រឹងកិច្ចសហប្រតិបត្តិការ | 1.3.1<br><br>1.3.2 | ចូលរួមជាមួយ CIPA និងបណ្ដាញផ្សេងៗ<br><br>ចូលរួមចំណែក និង គាំទ្រយន្តការរបស់ CIPA ក្នុងការគៀងគរសំលេង ជ.ត និងសកម្មភាពតស៊ូមតិ | - កំណត់ហេតុប្រជុំត្រីមាសរបស់បណ្ដាញ<br>- ឯកសារយន្តការ<br>- លិខិតបញ្ជាក់សមាជិកភាព<br>- សេចក្តីថ្លែងការ និងរបាយការណ៍<br>- តារាងគណៈកម្មការ ជ.ត<br>- ឯកសារយោងរបស់គណៈកម្មការ និង តំណាង | បានលះបង់ដើម្បីផលប្រយោជន៍រួម<br>- ចូលរួមកិច្ចប្រជុំប្រចាំខែ ត្រីមាស និង ប្រចាំឆ្នាំ រៀបចំដោយ CIPA<br>- ចូលរួមកិច្ចប្រជុំបន្ទាន់រៀបចំដោយ CIPA និង អ្នកពាក់ព័ន្ធផ្សេងៗទៀតដើម្បីលើកកំពស់សិទ្ធិ ជ.ត និង ដោះស្រាយបញ្ហារបស់ ជ.ត<br>- រួមចំណែកបង្កើតទិវា ជ.ត និងព្រឹត្តិការណ៍ផ្លាស់ប្តូរវប្បធម៌ផ្សេងៗទៀត<br>- គៀងគរគណៈកម្មការ ជ.ត (ពេញផ្ទៃប្រទេស) និងបង្កើតបណ្ដាញ<br>- សម្របសម្រួលប្រជុំបណ្ដាញពង្រឹងកិច្ចសហប្រតិបត្តិការ និងជម្រុញឱ្យអនុវត្តតាមលទ្ធផលឆ្លុះបញ្ចាំងក្នុងឆ្នាំ ២០១៦ ។ | - បន្តរៀបចំផែនការយុទ្ធសាស្ត្របណ្ដាញជាតិនៃស/គចុះជានីតិបុគ្គល<br>- ដូចក្នុងឆ្នាំ២០១៧<br>- ផ្តល់បច្ចេកទេស និងថវិការគាំទ្រដល់បណ្ដាញ ជ.ត និងអ្នកតំណាងដើម្បីធ្វើការតស៊ូមតិលើកង្វល់ របស់ ជ.ត ជាមួយអាជ្ញាធរមូលដ្ឋាន និងរដ្ឋាភិបាលថ្នាក់ | - បញ្ចប់ផែនការយុទ្ធសាស្ត្របណ្ដាញជាតិនៃស/គចុះជានីតិបុគ្គល<br>- ដូចឆ្នាំ ២០១៨<br>- ធ្វើការឆ្លុះបញ្ចាំង និង កត់ត្រាការរៀនសូត្រ | - ដូចឆ្នាំ ២០១៩<br>- វាយតម្លៃ និងផ្តល់អនុសាសន៍សម្រាប់ធ្វើផែនការអនាគត់ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ណើរការសិក្សារៀនសូត្រចាប់តាំងពីឆ្នាំ ២០១១។ បច្ចុប្បន្ននេះមានក្រុមការងារស្នូល(៨អង្គការ)ដើម្បីធ្វើផែនទីដើរជាមួយគ្នាក្នុងការបង្កើតឲ្យមានបណ្តាញផ្លូវការចេញពីមូលដ្ឋាន ទៅដល់ថ្នាក់ជាតិ | | | | | - រៀបចំសិក្ខាសាលាយុទ្ធសាស្រ្តបង្កើតបណ្តាញសម្ព័ន្ធសម្រាប់ផែនការបន្ត<br>- ទំនាក់ទំនង និងយុទ្ធនាការតស៊ូមតិនៅក្នុងប្រទេស | ជាតិ។ | | |
| • គ/ណ ឬតំណាងស/គមានស្រាប់នៅស/គ ថ្នាក់ខេត្ត និងថ្នាក់ជាតិប៉ុន្តែសមត្ថភាពនៅមិនទាន់ខ្លាំង និងជឿជាក់ដើម្បីតស៊ូមតិការងារប្រ | 1.4 កសាង និង ពង្រឹងសមត្ថភាពជនជាតិដើមភាគតិច | 1.4.1 | គណៈកម្មការ ជ.ត និង សកម្មជនបង្ហាញទំនុកចិត្តក្នុងការដឹកនាំ និង ធ្វើការតស៊ូមតិ ដើម្បី | - របាយការណ៍កសាងសមត្ថភាព<br>- តារាងប្រធានបទ និង ជំនាញដែលបានបណ្តុះបណ្តាល<br>- សៀវភៅស្តីពីសិទ្ធិ ជ.តលើដីធ្លី | - រៀបចំសិក្ខាលាសាស្តីពីផែនការយុទ្ធសាស្រ្តជាតិ និងផែនការជាមួយសហគមន៍ជ.ត<br>- ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីក្របខ័ណ្ឌការងារ Nevigator ដល់ដៃគូអង្គការជនជាតិដើមភាគតិច និងអ្នកពាក់ពន្ធផ្សេងៗ<br>- បណ្តុះបណ្តាលកសាងសមត្ថភា | - បណ្តុះបណ្តាលកសាងសមត្ថភាពស្ថាប័នជនជាតិដើមភាគតិចដើម្បីផ្សារភ្ជាប់ជាមួយដៃគូអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។ | - រៀបចំសម្របសម្រួលកិច្ចសន្ទនាសង្គមដើម្បីផ្សារភ្ជាប់ជនជាតិដើមភាគតិចជាមួយថ្នាក់ជាតិ និងអន្តរជាតិដើម្បីធ្វើផែនការយុទ្ធសាស្រ្តជាតិ<br>- សមាជិកគណៈកម្ម | - សមាជិកគណៈកម្មការចំនួន៤៤៩នាក់ (ស្រ្តី ២៣៩នាក់) និង សកម្មជនបាន ទទួលការប |

| | | | | | | | |
|---|---|---|---|---|---|---|---|
| យោជន៍និងសិទ្ធិរបស់ពួកគេ។ ចំនុចនេះគឺផ្អែកលើការតាមដាននឹងសង្កេតពីសារពត៌មាន និងទំនាក់ទំនងការងារសាធារណៈ។ ភាគច្រើនអ្នកដែលធ្វើការតស៊ូមតិជួយជនជាតិគឺគឺមិនមែនជាជនជាតិដើមភាគតិច | | ផលប្រយោជន៍ សហគមន៍ ជ.ត (និង បានភ្ជាប់ ទំនុកចិត្តនេះ ទៅ នឹងការកសាង សមត្ថភាពរបស់ អ.ជ.ក) | និង ព្រំប្រទល់<br>- របាយការណ៍រីកចម្រើន និង ប្រចាំឆ្នាំ<br>- ប្រវត្តិសហគមន៍ | ពស្ថាប័នជនជាតិដើមភាគតិច ដើម្បីផ្សារភ្ជាប់ជាមួយដៃគូអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។<br>- រៀបចំសម្របសម្រួលកិច្ចសន្ទនាសង្គមដើម្បីផ្សារភ្ជាប់ ជនជាតិដើមភាគតិច ជាមួយថ្នាក់ជាតិ និងអន្តរជាតិដើម្បីធ្វើផែនការយុទ្ធសាស្ត្រជាតិ | - រៀបចំសម្របសម្រួលកិច្ចសន្ទនាសង្គមដើម្បីផ្សារភ្ជាប់ ជនជាតិដើមភាគតិច ជាមួយថ្នាក់ជាតិ និងអន្តរជាតិដើម្បីធ្វើផែនការយុទ្ធសាស្ត្រជាតិ | ការចំនួន ៤៤៩នាក់ (ស្ត្រី ២៣៩នាក់) និង សកម្មជនបានទទួលការបណ្តុះបណ្តាល និង បង្វឹក<br>- ជ.ត ចំនួន ៤៤៩ នាក់បានទទួលការបណ្តុះបណ្តាល និងបង្កើនភាពអង់អាច<br>- សម្របសម្រួលកិច្ចសន្ទនាសង្គមចំនួនពីរដើម្បីផ្តល់យោបល់ត្រឡប់លើដំណើរការ និង លទ្ធផលចងក្រងផែនការវិនិយោគឃុំ ។ | ណ្តុះបណ្តាល និង បង្វឹក<br>- ជ.ត ចំនួន ៤៤៩ នាក់បានទទួលការបណ្តុះបណ្តាល និង បង្កើនភាពអង់អាច ។<br>- វាយតម្លៃ និង ផ្តល់អនុសាសន៍សម្រាប់ធ្វើផែនការអនាគត ។ |
| | 1.4.2 | ជ.ត មានភាពក្លាហានក្នុងការ ចូលរួមកិច្ចសន្ទនាសង្គម និង យុទ្ធនាការតស៊ូមតិ ឧ. លើ ការគ្រប់គ្រង | | - ពង្រឹង និងកសាងសមត្ថភាព និងលើកកម្ពស់សិទ្ធិជនជាតិដើមភាគតិចលើដីធ្លី និងដែនដី | - សមាជិកគណៈកម្ម ការចំនួន ៤៤៩នាក់ (ស្ត្រី ២៣៩នាក់) និង សកម្មជនបានទទួលការបណ្តុះបណ្តាល និងបង្វឹក។<br>- ជ.ត ចំនួន ៤៤៩ នាក់បានទទួលការ | | |

| | |
|---|---|
| ធនធានធម្មជាតិ និង ការធ្វើឱ្យប្រសើរឡើងនៃសេវាសាធារណៈ (ហើយពួកគេបានភ្ជាប់ភាពក្លាហាននេះទៅនឹងការកសាង សមត្ថភាពរបស់ អ.ជ.ក) | បណ្តុះបណ្តាល និង បង្កើនភាពអង់អាច ។<br>- សម្របសម្រួលកិច្ចសន្ទនាសង្គមចំនួន ពីរដើម្បីជ្រើសរើស បញ្ហាជាអាទិភាពរបស់ ជ.ត ដាក់បញ្ចូលក្នុងផែនការ វិនិយោគឃុំ ។ |

## យុទ្ធសាស្ត្រទី ២ ៖ ការតស៊ូមតិ និង ជួយរដ្ឋាភិបាលឱ្យពន្លឿនដំណើរការចុះបញ្ជីដីសហគមន៍

| គោលបំណង | | សូចនាករ | មធ្យោបាយវាស់វែង | លទ្ធផលចំបងៗ | | | |
| --- | --- | --- | --- | --- | --- | --- | --- |
| | | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
| • ត្រឹមខែ ១២ ឆ្នាំ ២០១៦ មានស/គចុះបញ្ជីស្វ័យអត្តសញ្ញាណចំនួន១១៩ ស/គ និងចំនួន ១០៩ នៅក្រសួងមហាផ្ទៃ | 2.1 កំណត់ឡើងវិញនូវគណកម្មការចុះបញ្ជីដី សហគមន៍ និង ពង្រឹងសមត្ថភាពរបស់ពួកគេ | 2.1.1 បានពិនិត្យ និង កំណត់ឡើងវិញលើសមាសភាពគណៈកម្មការចុះបញ្ជីដីសហគមន៍ទាំងអស់<br>2.1.2 គណៈកម្មការចុះបញ្ជីដីសហគមន៍ទាំង ១១៩ បានពង្រឹងតួនាទីរបស់ពួកគេ តាមរយៈការកសាង | - តារាងឈ្មោះគណកម្មការចុះបញ្ជីដី សហគមន៍<br>- កំណត់ហេតុប្រជុំជាមួយសមាជិកសហគមន៍ ជ.ត | - គាំទ្រគណកម្មការចុះបញ្ជីដីសហគមន៍ ចំនួន ៥ ឱ្យមានឯកសារចុះបញ្ជីដី (ផែនទី និងឯកសារផ្ទៃក្នុង) ដើម្បីដាក់ស្នើរចុះបញ្ជីដីសហគមន៍។<br>- ដំណើរការពិនិត្យ និងកំណត់សមាសភាពគណកម្មការចុះបញ្ជីដី សហគមន៍ទាំង ១១៩ (សរុប ១១៩ គណៈកម្មការនៅជុំវិញតំបន់អភិរក្ស)<br>- ពង្រឹងសមត្ថភាពសមាជិកគណៈកម្មការចុះបញ្ជីដីសហគមន៍ដើម្បីឲ្យមានប្រសិទ្ធិភាពក្នុងការប្រើប្រាស់ដីតាមរយៈការរៀបចំវគ្គបណ្តុះបណ្តា | - ពង្រឹងសមត្ថភាពសមាជិកគណៈកម្មការចុះបញ្ជីដីសហគមន៍ដើម្បីឲ្យមានប្រសិទ្ធិភាពក្នុងការប្រើប្រាស់ដីតាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលចំនួន២ ដលើស/គចុះបញ្ជីចំនួន ២០<br>- រៀបចំវេទិការវាងស/គ ជ.ត ក្រុមហ៊ុន សង្គមស៊ីវិល និងរាជរដ្ឋាភិបាល ដើម្បី | - ពង្រឹងសមត្ថភាពសមាជិកគណៈកម្មការចុះបញ្ជីដីសហគមន៍ដើម្បីឲ្យមានប្រសិទ្ធិភាពក្នុងការប្រើប្រាស់ដីតាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលចំនួន ២ ដលើស/គចុះបញ្ជីចំនួន២០<br>- រៀបចំវេទិការវាងស/គ ជ.ត ក្រុមហ៊ុន សង្គមស៊ីវិល និងរាជរដ្ឋាភិបាល ដើម្បីពិភាក្សាសិទ្ធិដីធ្លី។<br>- រៀបចំទស្សនៈកិច្ច | - ដូចឆ្នាំ ២០១៩<br>- វាយតម្លៃ និងផ្តល់អនុសាសន៍សម្រាប់ធ្វើផែនការអនាគត |

| | | | |
|---|---|---|---|
| សមត្ថភាពរបស់ អ.ជ.ក | លចំនួន២ ដលើ ស/គចុះបញ្ជីចំនួន២០<br>- រៀបចំវេទិការវាងស/គ ជ.ត ក្រុមហ៊ុន  សង្គមស៊ីវិល និងរាជរដ្ឋាភិបាលដើម្បី ពិភាក្សាសិទ្ធិដីធ្លី។<br>- រៀបចំគម្រូស/គជ.ត ជានីតិបុគ្គល និងចុះបញ្ជីដីស/គនៅក្នុង ស/គចំនួន ៥ ដើម្បីពង្រឹងប្រសិទ្ធិភាពនៃ ការប្រើប្រាស់ដីសមូ ហភាព<br>- រៀបចំទស្សនៈកិច្ចសិក្សាផ្លាស់ប្ដូរបទ ពិសោធន៍ក្នុងស/គ នីតិបុគ្គលដើម្បីរៀន សូត្រលើគម្រូនៃភាពជោគជ័យ<br>- រៀបចំរៀនសូត្រឆ្លុះបញ្ចាំងសិក្ខាសាលាក្នុងចំណោមស/គ  ជ.ត<br>- តាមដាន និងជួយ ស/គជានីតិបុគ្គល | ពិភាក្សាសិទ្ធិដីធ្លី។<br>- រៀបចំទស្សនៈកិច្ចសិក្សាផ្លាស់ប្ដូរបទ ពិសោធន៍ក្នុងស/គ នីតិបុគ្គលដើម្បីរៀន សូត្រលើគម្រូនៃ ភាពជោគជ័យ<br>- រៀបចំរៀនសូត្រ ឆ្លុះបញ្ចាំងសិក្ខាសាលា ក្នុងចំណោមស/គ ជ.ត<br>- តាមដាន និងជួយ ស/គជានីតិបុគ្គល | សិក្សាផ្លាស់ប្ដូរបទ ពិសោធន៍ក្នុងស/គ នីតិបុគ្គលដើម្បីរៀន សូត្រលើគម្រូនៃភាពជោគជ័យ<br>- រៀបចំរៀនសូត្រឆ្លុះ បញ្ចាំងសិក្ខាសាលា ក្នុងចំណោមស/គ ជ.ត<br>- តាមដាន និងជួយ ស/គជានីតិបុគ្គល |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| • ត្រឹមខែ ៣ ឆ្នាំ ២០១៧ មានស/គចុះបញ្ជីដីសមូហភាព (មានប្លង់ដីសមូហភាព) ចំនួន ១៤ ដែលបានគាំទ្រដោយអង្គការជាតិផ្សេងៗ រួមទាំងរាជរដ្ឋាភិបាល<br>• មានស/គ៥១ បានដាក់ពាក្យសុំចុះបញ្ជីដីសមូហភាព និង៤៥ ស/គបានទទួលវិធានការការពារ | 2.2 ជ.ត បានទទួលកម្មសិទ្ធ ដីពីរដ្ឋាភិបាល | 2.2.1 | ដីសហគមន៍ត្រូវបានចុះបញ្ជី | - វិញ្ញាប័នបត្តិចុះបញ្ជីដីធ្លី<br>- របាយការកម្មវិធី<br>- កំណត់ហេតុប្រជុំគណៈគ្រប់គ្រង អ.ជ.ក | - កំណត់សហគមន៍ដែលមានបញ្ហា និងសិក្សាពីបញ្ហាដែលរាំងស្ទះដល់ដំណើរការចុះបញ្ជី។<br>- ពិភាក្សាជាមួយ ក្រសួងពាក់ព័ន្ធ (MRD, MoE, MoI and MLMUP) រកដំណោះស្រាយគ្រប់បញ្ហាចុះបញ្ជីដី សហគមន៍។<br>- សហការជាមួយ CIPA, CEDT[10] និង បណ្តាញផ្សេងៗ ដើម្បីទទួលបានជំនួយបច្ចេកទេស (ឧ ៖ គូរផែនទីបឋម សហគមន៍) សម្រាប់ ចុះបញ្ជីដីសហគមន៍ | - បន្តការពិភាក្សាជាមួយក្រសួងពាក់ព័ន្ធ (MRD, MoE, MoI and MLMUP) រកដំណោះស្រាយគ្រប់បញ្ហាចុះបញ្ជីដី សហគមន៍ ។<br>- សហការជាមួយបណ្តាញទាំងអស់រៀបចំឯកសារផ្លូវច្បាប់ ដើម្បីដាក់សំណើរចុះបញ្ជីសារជាថ្មីចំពោះដីសហគមន៍ដែលនៅ សេសសល់ទាំងអស់ ។ | - ដូចឆ្នាំ ២០១៨<br>- ធ្វើការឆ្លុះបញ្ចាំង និង កត់ត្រាការរៀនសូត្រ | - ដូចឆ្នាំ ២០១៩<br>- វាយតម្លៃ និង ផ្តល់អនុសាសន៍សម្រាប់ធ្វើផែនការអនាគត |

10 CEDT: The Community Empowerment and Development Teams, who specialized in producing community land maps

បណ្ដាះអាសន្ន នៅខេត្តចំនួន ៧ ស្រុកចំនួន៦ និងឃុំចំនួន ១៤។

---

| យុទ្ធសាស្រ្តទី ៣ ៖ ពង្រឹងជីវភាព និងសកម្មភាពសេដ្ឋកិច្ចរបស់សហគមន៍ជនជាតិដើមភាគតិច | | | | | | | |
|---|---|---|---|---|---|---|---|
| | គោលបំណង | សូចនាករ | មធ្យោបាយវាស់វែង | លទ្ធផលចំបងៗ | | | |
| | | | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
| • នៅមិនទាន់មានផែនការរួម ប៉ុន្តែមានផែនការជាលក្ខណៈឯកជន ផ្សេងៗគ្នាដែលបានដាក់បញ្ចូលក្នុងផែនការវិនិយោគឃុំ ប៉ុន្តែមិនទាន់បានអ/នុ ពីព្រោះឃុំផ្តោត | 3.1 ធ្វើការពិនិត្យឡើងវិញចំពោះគ្រួសារ ជ.ត ដែលក្រីក្រ និង ត្រូវការជំនួយខ្លាំងបំផុត។ | 3.1.1 តម្រូវការ និង អនុសាសន៍របស់ជ.តដែលបានកំណត់ និងបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្រ្តជាតិ និង ផែនការវិនិយោគឃុំ<br>3.1.2 ក្រុមប្រឹក្សាឃុំបញ្ចូល | - របាយការណ៍អង្កេតបឋម<br>- របាយការណ៍ជីវភាពសហគមន៍<br>- របាយការណ៍ប្រចាំ ឆ្នាំ<br>- របាយការណ៍ត្រួតពិនិត្យ និង វាយតម្លៃ | - រៀបចំសិក្ខាសាលាដែលមានការចូលរួមពីស/គ ដើម្បីកំណត់ និងចាត់ អទិភាពតម្រូវ និងការរៀបចំផែនការសកម្មភាពជាក់លាក់លម្អិតដើម្បីសាកល្បងរួមទាំងតាមដានការអនុវត្តដៃគូនៅថ្នាក់ជាតិ<br>- បញ្ចូលផែនការដែលបានរកឃើញ និងផ្សព្វផ្សាយដល់អ្នកគោលនយោបាយ និងអ្នកធ្វើកម្មវិធីនៅថ្នាក់មូល | - បច្ចុប្បន្នពីតម្រូវការ ស/គ<br>- ផ្តល់បច្ចេកទេសជាទៀងទាត់ដល់ក្រុមការងារតាមរយៈ (ប្រជុំប្រចាំខែ ត្រីមាស និងឆ្នាំ) ជាមួយស/គគោល ដៅ<br>- ធ្វើអង្កេតទីផ្សារ | - បច្ចុប្បន្នពីតម្រូវការ ស/គ<br>- ផ្តល់បច្ចេកទេសជាទៀងទាត់ដល់ក្រុមការងារតាមរយៈ (ប្រជុំប្រចាំខែ ត្រីមាស និងឆ្នាំ) ជាមួយស/គគោលដៅ<br>- ធ្វើអង្កេតទីផ្សារសម្រាប់លក់ផលិតផលកសិកម្ម | - កត់ត្រាការរៀន សូត្រ និង ផ្តល់អនុសាសន៍សម្រាប់ធ្វើផែនការអនាគត |

| | | | | |
|---|---|---|---|---|
| លើការកសាង<br>ហេដ្ឋារចនាសម្ព<br>ន្ធ័។<br>និងមិនមានថវិ<br>កាដោះស្រាយប<br>ញ្ហាស/គក្នុងផែ<br>នការអ/ភិស/គ<br>ដែលបានដាក់ប<br>ញ្ចូលក្នុងផែនកា<br>រវិនិយោគឃុំ<br>• មិនមានទិន្នន័យ<br>ឬភស្តុតាងដើម្បី<br>បង្ហាញថាក្រុម<br>ប្រឹក្សាឃុំបាន<br>ដោះស្រាយពីត<br>ម្រូវការស/គក្នុង<br>ផែនការវិនិយោ<br>គឃុំ<br>និងមិនមានប្រព<br>ន្ធតាមដានត្រួត<br>ពិនិត្យលើការអ | និងអន្តរាគមជា<br>ក់<br>ឬដោះស្រាយប<br>ញ្ហារបស់ ជ.ត<br>ក្នុង<br>ផែនការវិនិយោ<br>គឃុំ | ដ្ឋាន និងថ្នាក់ជាតិ (ជាវីដេអូ<br>សម្លេង និងរបាយការណ៍)<br>រួមទាំងចង់ក្រងបទ ពិសោធន៍<br>និងគម្រូ ល្អស្ដីពីសិទ្ធិមូលដ្ឋាន<br>វប្បធម៌<br>និងការចូលរួមក្នុងសង្គម<br>និងការការ<br>ពារពីសង្គមសម្រាប់ជ.ត<br>- ជ្រើសរើសគ្រួសារ<br>(ក្នុងសហគមន៍ គោលដៅ)<br>និងផ្តល់ការកសាងសមត្ថភាព(<br>៦ដង)<br>ដើម្បីឱ្យពួកគេអាចអនុវត្តផែន<br>ការអភិវឌ្ឍន៍ និងជំនួញ<br>សម្រាប់គ្រួសារ។<br>- ផ្តល់ជំនួយបច្ចេកទេស<br>និងថវិការ ដល់ស/គគោលដៅ<br>(ឧ. ជួយស/គឡា<br>អិនអនុវត្តគម្រោង<br>ស្តីពីស្ត្រីជាអ្នកដឹក<br>នាំលើការគ្រប់គ្រងធនធានធម្ម | សម្រាប់លក់<br>ផលិតផលកសិក<br>ម្ម<br>របស់សហគមន៍<br>ជ.ត ។<br>- រៀបចំកិច្ចប្រជុំ<br>ក្រុមការងារ<br>បច្ចេកទេស<br>(ប្រចាំ ខែ<br>ត្រីមាស និង<br>ប្រចាំឆ្នាំ) ។<br>- ផ្លាស់ប្តូរចំណេះដឹ<br>ងនិង<br>បទពិសោធន៍<br>ក្នុងសហគមន៍ ឬ<br>ក្រុមការងារ<br>កសិកម្មដែលមាន<br>សក្តានុពលក្នុង<br>ប្រទេសឬក្នុងតំប<br>ន់ (១ឆ្នាំ ម្តង) | របស់សហគមន៍<br>ជ.ត ។<br>- រៀបចំកិច្ចប្រជុំ<br>ក្រុមការងារ<br>បច្ចេកទេស (ប្រចាំ<br>ខែ ត្រីមាស និង<br>ប្រចាំឆ្នាំ) ។<br>- ផ្លាស់ប្តូរចំណេះដឹង<br>និង បទពិសោធន៍<br>ក្នុងសហគមន៍ ឬ<br>ក្រុមការងារ<br>កសិកម្មដែលមាន<br>សក្តានុពលក្នុង<br>ប្រទេសឬក្នុងតំបន់<br>(១ឆ្នាំ ម្តង) |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| នុវត្ត | | | | | ជាតិ និងអេកូទេស ចរណ៏ និងនៅស/គ ល្បីនជងស្តីពីការពង្រឹងអំណាចសិទ្ធិស្ត្រីជនជាតិដើមភាគតិចលើ ធនធានធម្មជាតិ និងការការពារប្រពៃណីវប្បធម៌) | | | |
| • នៅមិនទាន់មាន ផែនការនៅឡើយ | 3.2 អភិវឌ្ឍន៍ និង ធ្វើឱ្យមាន និរន្តរភាពអាជីវកម្មរបស់ ជ.ត ក្នុងតំបន់គោលដៅដែលបាន ជ្រើសរើស ។ | 3.2.1 | គ្រួសារជ.ត (ច្រើនជាង៥០% នៃចំនួនដែលមានស្រាប់) មានចំណូលទៀងទាត់ និង មាន និរន្តរភាពអាជីវកម្ម ។ | - របាយការណ៍គណៈគ្រប់គ្រង អ.ជ.ក<br>- ឯកសារទិន្នន័យ អង្កេតបឋម និង អង្កេតចុងក្រោយ<br>- ករណីសិក្សាលើ ប្រតិបត្តិការអាជីវកម្ម<br>- ផែនការវិនិ | - អនុវត្តគម្រោងសាកល្បងក្នុងភូមិ គោលដៅឬថ្នាក់ស្រុកក្នុងគោលបំណងធ្វើឲ្យ ប្រសើរឡើងនូវការ ទទួលបានសិទ្ធិវប្បធម៌ និងការចូលរួមក្នុងសេវាសង្គម និងការការពារពី សង្គម។<br>- កសាងសមត្ថភាព ក្រុម ជ.តដែលបាន ជ្រើសរើស អំពីការ បង្កើត និង គ្រប់គ្រងប្រតិបត្តិ ការអាជីវកម្ម។<br>- រៀបចំពិធីសំណេះ | - អនុវត្តគម្រោងសាកល្បងក្នុងភូមិ គោលដៅឬថ្នាក់ ស្រុកក្នុងគោលបំណងធ្វើឲ្យប្រសើរ ឡើងនូវការ ទទួលបានសិទ្ធិវប្បធម៌ និងការចូលរួមក្នុង សេវាសង្គម និងការការពារពី សង្គម។<br>- កសាងសមត្ថភាព ក្រុម | - អនុវត្តគម្រោងសាកល្បងក្នុងភូមិ គោលដៅឬថ្នាក់ស្រុកក្នុងគោលបំណង ធ្វើឲ្យប្រសើរឡើងនូវការ ទទួលបានសិទ្ធិវប្បធម៌ និងការចូលរួមក្នុង សេវាសង្គម និងការការពារពី សង្គម។<br>- កសាងសមត្ថភាព ក្រុម ជ.តដែលបាន | - អនុវត្តគម្រោងសាកល្បង ក្នុងភូមិ គោលដៅឬ ថ្នាក់ស្រុកក្នុងគោលបំណងធ្វើឲ្យ ប្រសើរឡើង នូវការ ទទួលបាន សិទ្ធិវប្បធម៌ និងការចូលរួមក្នុងសេវា សង្គម |

| | | | | |
|---|---|---|---|---|
